**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# ការការពាររុក្ខជាតិ និងភូតគាមអនាម័យ

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

# មាតិកា


**ជំពូកទី១ បទប្បញ្ញត្តិទូទៅ** ...................................................................................៣

**ជំពូកទី២ សមត្ថកិច្ចគ្រប់គ្រង** ..............................................................................៤

**ជំពូកទី៣ ការការពាររុក្ខជាតិ**.................................................................................៧

ផ្នែកទី១ ៖ វិធានរួមសម្រាប់ការការពាររុក្ខជាតិនិងផលិតផលរុក្ខជាតិ ........................... ៧

ផ្នែកទី២ ៖ វិធានការបង្ការ និងកម្ចាត់សមាសភាពចង្រៃ.......................................... ១០

ផ្នែកទី៣ ៖ វិធានការទប់ស្កាត់ផលប៉ះពាល់ពីការការពាររុក្ខជាតិនិងផលិតផលរុក្ខជាតិ.... ១៤

**ជំពូកទី៤ ការត្រួតពិនិត្យភូតគាមអនាម័យ**............................................................១៦

ផ្នែកទី១ ៖ វិធានរួមនៃការត្រួតពិនិត្យភូតគាមអនាម័យ ........................................... ១៦

ផ្នែកទី២ ៖ ការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ ................................................ ២០

ផ្នែកទី៣ ៖ ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូល.................................២២

ផ្នែកទី៤ ៖ ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ និងទំនិញនាំចេញបន្ត ... ២៦

ផ្នែកទី៥ ៖ ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់ ...............................២៧

**ជំពូកទី៥ ការគ្រប់គ្រងការរាលដាលឆ្លងសមាសភាពចង្រៃ**.................២៩

ផ្នែកទី១ ៖ តំបន់រាលដាលឆ្លងសមាសភាពចង្រៃ .................................................. ២៩

ផ្នែកទី២ ៖ វិធានការភូតគាមអនាម័យ ................................................................. ៣១

**ជំពូកទី៦ បញ្ជីសមាសភាពចង្រៃនិងការវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ** ...............................................................................................៣៦

**ជំពូកទី៧ យន្តការគាំទ្រការការពាររុក្ខជាតិនិងភូតគាមអនាម័យ** ........៣៨

ផ្នែកទី១ ៖ ការស្រាវជ្រាវ និងការពង្រឹងសមត្ថភាពភូតគាមអនាម័យ........................ ៣៨

ផ្នែកទី២ ៖ មូលនិធិបន្ទាន់សម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ ............... ៤០

**ជំពូកទី៨ ការគ្រប់គ្រងព័ត៌មានភូតគាមអនាម័យ និងការផ្សព្វផ្សាយ** ៤១

**ជំពូកទី៩ ភាគព្វកិច្ចប្រតិបត្តិករ**...............................................................................៤៣

**ជំពូកទី១០ ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ និងការជំរុញអនុវត្តន៍ច្បាប់** ...............................................................................................៤៤

**ជំពូកទី១១ ទោសប្បញ្ញត្តិ**.....................................................................................៤៨

**ជំពូកទី១២ អន្តរប្បញ្ញត្តិ** ........................................................................................៥៧

**ជំពូកទី១៣ អវសានប្បញ្ញត្តិ** ...................................................................................៥៧

**ឧបសម្ព័ន្ធ សន្ទានុក្រម**

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ច្បាប់នេះមានគោលបំណង កំណត់ការគ្រប់គ្រងការពាររុក្ខជាតិ និងភូតគាមអនាម័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

ច្បាប់នេះមានគោលដៅ៖

-ធានាការគ្រប់គ្រងសុខភាពរុក្ខជាតិតាមរយៈការអនុវត្តវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ ដើម្បីកាត់បន្ថយហានិភ័យ និងការខាតបង់ដែលអាចបង្កឡើងដោយសមាសភាពចង្រៃចំពោះធនធានរុក្ខជាតិនិងផលិតផលដំណាំ នៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម -ធានាការកាពារធនធានរុក្ខជាតិគ្រប់ប្រភេទតាមរយៈការទប់ស្កាត់ការបង្ក ការរាលដាលឆ្លង និងការរាតត្បាតពីសំណាក់សមាសភាពចង្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-លើកកម្ពស់ផលិតភាពកសិកម្មនិងសន្តិសុខស្បៀង ដោយធានាអនាម័យ គុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម ព្រមទាំងធានាសន្តិសុខភូតគាមអនាម័យនៃរុក្ខជាតិផលិត ផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ

-សម្រួលការធ្វើពាណិជ្ជកម្ម ការនាំចេញ ការនាំចូល ការដឹកជញ្ជូនឆ្លងកាត់ផលិតផលដំណាំ រុក្ខជាតិ និងផលិតផលរុក្ខជាតិស្របតាមលក្ខខណ្ឌតម្រូវនៃវិធានការអនាម័យនិងភូតគាមអនាម័យក្នុងប្រទេស តំបន់ និងអន្តរជាតិ

-រួមចំណែកការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិតាមរយៈការជំរុញផលិតកម្មកសិកម្ម និងពាណិជ្ជកម្មផលិតផលកសិកម្ម ប្រកបដោយគុណភាពនិងសុវត្ថិភាព ស្របតាមលក្ខខណ្ឌតម្រូវនៃទីផ្សារក្នុងស្រុកនិងក្រៅស្រុក

-រួមចំណែកលើកកម្ពស់សុខុមាលភាព និងសុខភាពសាធារណៈដោយធានាបាននូវនិរន្តភាពធនធានធម្មជាតិនិងប្រព័ន្ធក្សេត្របរិស្ថាន ។

**មាត្រា៣.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់ចំពោះ៖

១-ធនធានរុក្ខជាតិ រុក្ខជាតិ ផលិតផលរុក្ខជាតិ និងផលិតផលដំណាំគ្រប់ប្រភេទដែលត្រូវអនុវត្តវិធានការការពាររុក្ខជាតិ និងរាល់ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាម
អនាម័យ។

២-ការគ្រប់គ្រងប្រព័ន្ធវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងប្រទេសឬដែនដីប្រភពដើមផលិតកម្មនៃដំណាំរុក្ខជាតិផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលមានបំណង
នាំចេញ នាំចូល ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា។

៣-គ្រប់សកម្មភាពរបស់រូបវន្តបុគ្គលឬនីតិបុគ្គល សាធារណៈឬឯកជន ដែលពាក់ព័ន្ធនឹងការអនុវត្តវិធានការកាពាររុក្ខជាតិឬវិធានការភូតគាមអនាម័យ
ក្នុងក្របខណ្ឌនៃការទប់ស្កាត់ការបង្ក
និងការរាលដាលឆ្លងសមាសភាពចង្រៃគ្រប់ប្រភេទនិងសព៌ាង្គកាយបង្កគ្រោះថ្នាក់ នៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥.-**

ការគ្រប់គ្រង និងការត្រួតពិនិត្យការការពាររុក្ខជាតិ និងភូតគាមអនាម័យ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បំពេញសមត្ថកិច្ចក្នុងការការពាររុក្ខជាតិ និងភូតគាមអនាម័យ ដោយអនុលោមតាមច្បាប់នេះ និងអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ(IPPC) ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគីហត្ថលេខី ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មាត្រា៦.-**

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអង្គភាពជំនាញ មានតួនាទី និងភារកិច្ចជំរុញ និងពង្រឹងការអនុវត្តច្បាប់នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ជាអង្គភាពជាតិការពាររុក្ខជាតិ (NPPO) ដែលបំពេញបេសកកម្ម និងភារកិច្ចដូចមានចែងក្នុងច្បាប់នេះ និងទទួលខុសត្រូវអនុវត្តរាល់កាតព្វកិច្ចពាក់ព័ន្ធរបស់ព្រះរាជាណាចក្រ

កម្ពុជា តាមការកំណត់របស់អនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ និងគណៈកម្មាការនៃវិធានការភូតគាមអនាម័យរបស់អនុសញ្ញានេះ។

## មាត្រា៧.-

ក្រោមវិសាលភាពនៃច្បាប់នេះ និងអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ នាយកដ្ឋាការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ក្នុងនាមជាអង្គភាពជាតិការពាររុក្ខជាតិត្រូវបំពេញបេសកកម្ម និងភារកិច្ចដូចខាងក្រោម៖

១-សិក្សា រៀបចំគោលនយោបាយ បទដ្ឋានគតិយុត្ត ស្តង់ដារ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ។

២-គ្រប់គ្រងប្រព័ន្ធការងារក្នុងក្របខណ្ឌនៃការអនុវត្តវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ កិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យនៃអង្គការពាណិជ្ជកម្មពិភពលោក ស្តង់ដារជាតិ តំបន់ និងអន្តរជាតិ ស្តីពីវិធានការភូតគាមអនាម័យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

៣-គ្រប់គ្រងស្ថានភាពសមាសភាពចង្រៃ ដោយអនុវត្តវិធានការការពាររុក្ខជាតិ ឬវិធានការភូតគាមអនាម័យចំពោះ រុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលធ្វើពាណិជ្ជកម្ម នាំចូល នាំចេញ ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រ កម្ពុជា។

៤-គ្រប់គ្រង និងត្រួតពិនិត្យសេវាកម្មបច្ចេកទេសគ្រប់ប្រភេទ ក្នុងការអនុវត្តវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយធានាការសិក្សា វាយតម្លៃប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ លើគុណភាព ប្រសិទ្ធភាព និងហានិភ័យគ្រោះថ្នាក់ នៃផលិតផលការពាររុក្ខជាតិគ្រប់ប្រភេទ ស្របតាមច្បាប់នេះ

និងបទប្បញ្ញត្តិពាក់ព័ន្ធ
ជាធរមាន។

៥-ធ្វើវិភាគហានិភ័យសមាសភាពចង្រៃធ្វើវិញ្ញាបនកម្ម ដោយចេញវិញ្ញាបនបត្រភូតគាមអនាម័យចំពោះរាល់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ។

៦-គ្រប់គ្រងព័ត៌មានភូតគាមអនាម័យ និងអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងជាសាធារណៈក្នុងក្របខណ្ឌនៃការអនុវត្តវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ។

៧-អនុវត្តកម្មវិធីស្រាវជ្រាវ និងការពង្រឹងសមត្ថភាពបច្ចេកទេស ជាយន្តការគាំទ្រការគ្រប់គ្រងការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

៨-អភិវឌ្ឍសមត្ថភាពធនធានមនុស្ស អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់គុណវុឌ្ឍិរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីជំរុញការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាព។

៩-សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន សង្គមស៊ីវិលនិងដៃគូរអភិវឌ្ឍន៍នានា ក្នុងក្របខណ្ឌនៃការគ្រប់គ្រងសុខភាពរុក្ខជាតិ និងភូតគាមចត្តាឡីសក៍ ដើម្បីចូលរួមអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាព។

១០-ធ្វើសហប្រតិបត្តិការអន្តរជាតិ ដោយបំពេញតួនាទីជាចំណុចការងារផ្លូវការតំណាងព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ ការអនុវត្តលិខិតុបករណ៍ អន្តរជាតិឬតំបន់ និងការចូលរួមរាល់វេទិកាអន្តរជាតិ ដែលពាក់ព័ន្ធការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

១១-សម្រួលការវិនិយោគរបស់ផ្នែកឯកជន ក្នុងក្របខណ្ឌនៃការគាំទ្រសេវាកម្មបច្ចេកទេស និងការពង្រឹងសមត្ថភាពសម្រាប់វិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យដើម្បីលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១២-តាមដាន ត្រួតពិនិត្យលើគ្រប់សកម្មភាពក្នុងប្រព័ន្ធវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ ព្រមទាំងចាត់វិធានការជំរុញការអនុវត្តច្បាប់នេះ និងបណ្តាបទដ្ឋានគតិយុត្តក្រោមច្បាប់នេះប្រកបដោយប្រសិទ្ធភាព។

១៣-បំពេញភារកិច្ចផ្សេងទៀតក្រោមវិសាលភាពនៃច្បាប់នេះ។

**មាត្រា៨.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធសម្រាប់ធានាការត្រួតពិនិត្យភូតគាមអនាម័យក្របខណ្ឌជាតិ ដោយត្រូវបង្កើតការិយាល័យសាខាភូតគាមអនាម័យប្រចាំតំបន់ស្ថានីយភូតគាមចត្តាឡីស័ក និងស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យនៅមាត់ច្រកព្រំដែនគ្រប់ប្រភេទ ឬនៅទីកន្លែងចាំបាច់ផ្សេងទៀតក្រោមលក្ខខណ្ឌតម្រូវនៃការអនុវត្តស្តង់ដារអន្តរជាតិស្តីពីវិធានការភូតគាមអនាម័យ ដែលអាចធានាបាននូវប្រសិទ្ធភាពនៃការបំពេញសមត្ថកិច្ចរបស់អង្គភាពជាតិការពាររុក្ខជាតិ។

ការបង្កើតស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យនៅមាត់ច្រកព្រំដែនគ្រប់ប្រភេទត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៣
## ការការពាររុក្ខជាតិ

### ផ្នែកទី១
### វិធានរួមសម្រាប់ការការពាររុក្ខជាតិនិងធនធានរុក្ខជាតិ

**មាត្រា៩.-**

រាជរដ្ឋាភិបាលត្រូវដាក់បញ្ញត្តិស្តីពីវិធានការសម្រាប់ការការពាររុក្ខជាតិ និងធនធានរុក្ខជាតិ ក្នុងគោលបំណងទប់ស្កាត់ការបង្ក ការរាលដាលឆ្លង និងការរាតត្បាតពីសំណាក់សមាសភាពចង្រៃគ្រប់ប្រភេទ ដើម្បីកាត់បន្ថយការខាតបង់រុក្ខជាតិនិងធនធានរុក្ខជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១០.-**

វិធានការការពាររុក្ខជាតិនិងធនធានរុក្ខជាតិត្រូវអនុលោមតាមគោលការណ៍ចម្បងដូចខាងក្រោម៖

១-ត្រូវអនុវត្តវិធានការឱ្យបានព្រមគ្នា និងជាប្រចាំ ដោយចាត់ទុកវិធានការបង្ការ ឬទប់ស្កាត់ជាមុនជាអាទិភាពចម្បង និងត្រូវចាត់វិធានការកម្ចាត់សមាសភាពចង្រៃឱ្យបានចំពេលវេលា និងទាន់ពេលវេលាដើម្បីធានាប្រសិទ្ធភាពនៃវិធានការ។

២-នៅក្នុងការសម្រេចចិត្តអនុវត្តវិធានការបំផ្លាញសមាសភាពចង្រៃត្រូវចាត់ទុកផលប្រយោជន៍រួមរបស់សង្គម ឬផលប្រយោជន៍ជាតិជាអាទិភាពចម្បងដែលមានសារៈសំខាន់យូរ អង្វែងខ្ពស់ជាងផលប្រយោជន៍ឯកជន ឬសមូហភាពដែលមានសារៈសំខាន់ចំពោះមុខ។

៣-ត្រូវអនុវត្តវិធានការចម្រុះគ្រប់គ្រងដំណាំ ដោយកំណត់យកជម្រើសចម្បងនូវវិធានការជីវសាស្ត្រ រូបសាស្ត្រ មេកានិក ឬវិធានការក្សេត្រសាស្ត្រ និងបទពិសោធន៍ប្រពៃណីរបស់សហគមន៍មូលដ្ឋាន ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់អវិជ្ជមាន ចំពោះមនុស្ស សត្វ និងប្រព័ន្ធក្សេត្របរិស្ថាន។

៤-អាចកំណត់យកវិធានការគីមីជាជម្រើសចុងក្រោយ ដើម្បីប្រើប្រាស់នៅពេលចាំបាច់ដោយត្រូវគោរព និងអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់ការប្រើប្រាស់ផលិតផលការពាររុក្ខជាតិ ដែលអាចទទួលបាននូវជីវប្រសិទ្ធភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ និងធានាសុវត្ថិភាពចំពោះមនុស្ស សត្វ និងពពួកសត្រូវធម្មជាតិព្រមទាំងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ជាអតិបរមាចំពោះប្រព័ន្ធក្សេត្របរិស្ថាន។

គោលការណ៍ណែនាំសម្រាប់វិធានការការពាររុក្ខជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា១១.-

រាល់ផលិតផលការពាររុក្ខជាតិគ្រប់ប្រភេទ ដែលអាចធ្វើពាណិជ្ជកម្ម ឬអាចប្រើប្រាស់បាននៅក្នុងការអនុវត្តវិធានការការពាររុក្ខជាតិ ឬវិធានការភូតគាមអនាម័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធានាការឆ្លងកាត់ដំណើរការសិក្សា វាយតម្លៃប្រកបដោយលក្ខណៈវិទ្យាសាស្ត្រលើគុណភាព ប្រសិទ្ធភាព និងហានិភ័យគ្រោះថ្នាក់ និងការទទួលយកនូវការវាយតម្លៃរបស់ អគ្គនាយកដ្ឋានកសិកម្ម ស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារអន្តរជាតិយថាប្រភេទនៃផលិតផលការពាររុក្ខជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## មាត្រា១២.-

ត្រូវបានហាមឃាត់ការនាំចូល ការដាំដុះ ការកាន់កាប់ ឬការចែកចាយ នូវសព៌ាង្គកាយបង្កគ្រោះថ្នាក់ រុក្ខជាតិចង្រៃ និងប្រភេទចំណូលថ្មីឈ្លានពានឬរាតត្បាត ដែលបង្កហានិភ័យ
ខូចខាត និងបំផ្លិចបំផ្លាញដល់រុក្ខជាតិ ធនធានរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីបរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសកំណត់បញ្ជីប្រភេទដំណាំហាមឃាត់ និងប្រភេទរុក្ខជាតិស្ថិតក្រោមលក្ខខណ្ឌ ដែលអាចអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្ម និងការដាំដុះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលធ្វើពាណិជ្ជកម្មឬធ្វើការដាំដុះប្រភេទដំណាំឬប្រភេទរុក្ខជាតិស្ថិតក្រោមលក្ខខណ្ឌ ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

នីតិវិធីសម្រាប់ប្រភេទរុក្ខជាតិស្ថិតក្រោមលក្ខខណ្ឌ ដែលអាចធ្វើពាណិជ្ជកម្មឬធ្វើការដាំដុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា១៣.-

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសិក្សារៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ ត្រូវដាក់ចេញនូវគោលដៅរយៈពេលវែង និងអាទិភាពនានា សម្រាប់គ្រប់គ្រងសុខភាពរុក្ខជាតិ និងធនធានរុក្ខជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា
និងកសាងសមត្ថភាពជំនាញដែលអាចបំពេញបេសកកម្មនិងភារកិច្ចដូចមានចែងក្នុងច្បាប់នេះ
។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យត្រូវមានកម្មវិធីសំខាន់ៗ ដូចខាងក្រោម៖

១-កម្មវិធីអភិវឌ្ឍន៍សេវាកម្មការពាររុក្ខជាតិ និងភូតគាមអនាម័យ ដោយធ្វើឱ្យប្រសើរនូវការត្រួតពិនិត្យ ការទប់ស្កាត់ ការលុបបំបាត់សមាសភាពចង្រៃគ្រប់ប្រភេទ រួមជាមួយជំងឺរាតត្បាត និងសព៌ាង្គកាយបង្កគ្រោះថ្នាក់ ព្រមទាំងប្រភេទចំណូលថ្មីឈ្លានពាន។

២-កម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធផលិតកម្មកសិកម្ម ដែលធានាសុវត្ថិភាពស្បៀងតាមរយៈការអនុវត្តកសិកម្មល្អ។

៣-កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការពង្រឹងសមត្ថភាពបច្ចេកទេស ការងារស្រាវជ្រាវវិទ្យាសាស្ត្រ និងការថែរក្សាចំណេះដឹងប្រពៃណីក្នុងការការពារ រុក្ខជាតិ និងភូតគាមអនាម័យ។

៤-កម្មវិធីធ្វើឱ្យប្រសើរភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជននៅក្នុងក្របខណ្ឌនៃការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

៥-កម្មវិធីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងជំនួយបច្ចេកទេសនៅថ្នាក់ជាតិ និងអន្តរជាតិ សម្រាប់ការអភិវឌ្ឍ ការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

៦-កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានទិន្នន័យ សម្រាប់ការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

៧-កម្មវិធីអភិវឌ្ឍន៍សុវត្ថិភាពស្បៀងប្រឈមចំពោះហានិភ័យនៃសំណល់ថ្នាំកសិកម្មឬសារធាតុបង្កផលប៉ះពាល់សុខភាព។

៨-កម្មវិធីអភិវឌ្ឍន៍សន្តិសុខភូតគាមអនាម័យចំពោះសុខភាពរុក្ខជាតិ ប្រឈមចំពោះហានិភ័យនៃការរាលដាលឆ្លង នៅក្នុងសកម្មភាពដឹកជញ្ជូនក្នុងស្រុក ក្រៅស្រុក ឬក្នុងសកម្មភាពពាណិជ្ជកម្មអន្តរជាតិ។

៩-កម្មវិធីអភិវឌ្ឍន៍ផ្សេងទៀត ក្រោមវិសាលភាពនៃការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

**មាត្រា១៤.-**

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ ត្រូវសម្រេចដោយរាជរដ្ឋាភិបាល និងត្រូវផ្សព្វផ្សាយជាសាធារណៈសម្រាប់ការចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ផែនការនេះត្រូវពិនិត្យឡើងវិញរៀងរាល់៥(ប្រាំ)ឆ្នាំម្តង ឬនៅពេលដែលចាំបាច់ ដើម្បីវាយតម្លៃនិងឆ្លុះបញ្ចាំងអំពីស្ថានភាព និងបច្ចុប្បន្នភាពនៃការអភិវឌ្ឍចុងក្រោយក្នុងក្របខណ្ឌនៃការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ និងលើកសំណើកែសម្រួលផែនការយុទ្ធសាស្ត្រជាតិនេះ តាមការចាំបាច់។

## ផ្នែកទី២
## វិធានការបង្ការ និងកម្ចាត់សមាសភាពចង្រៃ

**មាត្រា១៥.-**

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ត្រូវបំពេញតួនាទីតាមដានជាប្រចាំ ចំពោះស្ថានភាពសុខភាពរុក្ខជាតិ ធនធានរុក្ខជាតិ ដោយត្រូវកំណត់វិធានការបង្ការ និងកម្ចាត់សមាសភាពចង្រៃនៅក្នុងកម្រិតជាតិ និង ត្រូវចូលរួមអនុវត្តវិធានការភូតគាមអនាម័យ ក្នុងកម្រិតអន្តរជាតិជាមួយបណ្តាប្រទេសជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិការពារ រុក្ខជាតិ។

ក្រោមគោលបំណងនៃការបង្ការ និងការកម្ចាត់សមាសភាពចង្រៃបំផ្លាញរុក្ខជាតិ និងធនធានរុក្ខជាតិ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ដោយសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ មាន ភារកិច្ច ដូចខាងក្រោម៖

១-អង្កេតស្វែងរកព្យាករណ៍ និងធ្វើការប្រកាសអំពីលទ្ធភាពរយៈពេលបង្ក ផ្ទៃដីរាតត្បាត កម្រិតបំផ្លាញរបស់សមាសភាពចង្រៃ និងផ្សព្វផ្សាយឱ្យទាន់ពេលវេលាដល់គោលដៅនូវវិធានការសមស្របដែលត្រូវអនុវត្ត។

២-តាមដានស្ថានភាពសុខភាពរុក្ខជាតិ និងធនធានរុក្ខជាតិនៅជុំវិញតំបន់ក្រោមដែនសមត្ថកិច្ចសាមី និង ចំណុចឆ្លងកាត់នៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិដើម្បីចាត់វិធានការទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃ និងកម្ចាត់សមាសភាពចង្រៃ។

៣-ត្រួតពិនិត្យស្ថានភាពសមាសភាពចង្រៃដែលបំផ្លាញរុក្ខជាតិ និងធនធានរុក្ខជាតិ និងអនុវត្តវិធានការកម្ចាត់សមាសភាពចង្រៃជាប្រចាំ នៅតាមតំបន់ផលិតកម្មកសិកម្ម កសិដ្ឋាន រោងចក្រកែច្នៃ មធ្យោបាយដឹកជញ្ជូន កំពង់ផែ ព្រលានយន្តហោះ ចំណតយានយន្ត ស្ថានីយ៍រថភ្លើង ប៉ុស្តិ៍ប្រៃសណីយ៍ ទីតាំងធ្វើពាណិជ្ជកម្ម ឬសន្និធិរុក្ខជាតិនិងផលិតផលរុក្ខជាតិ និងកន្លែងដទៃទៀតដែលមានសកម្មភាពពាក់ព័ន្ធនឹងរុក្ខជាតិនិងធនធានរុក្ខជាតិ ដោយផ្តល់ការណែនាំ ឬតម្រូវឱ្យម្ចាស់កសិដ្ឋានឬម្ចាស់ទីតាំងសាមីចាត់វិធានការបង្ការកម្ចាត់សមាសភាពចង្រៃ ឬកែតម្រូវការអនុវត្តវិធានការមិនសមស្របក្នុងការគ្រប់គ្រងសមាសភាពចង្រៃ ក្នុងគោលបំណងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានចំពោះផលប្រយោជន៍សាធារណៈ។

៤-ជំរុញចលនាមហាជនក្នុងមូលដ្ឋាន រួមមានអាជ្ញាធរដែនដីគ្រប់ថ្នាក់ សមត្ថកិច្ចពាក់ព័ន្ធផ្នែកឯកជន ម្ចាស់កសិដ្ឋាន ម្ចាស់ទីតាំងដូចបានរៀបរាប់ក្នុងចំណុច៣ខាង និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមសហការក្នុងប្រតិបត្តិការបង្ការ និងកម្ចាត់សមាសភាពចង្រៃដែលបំផ្លាញរុក្ខជាតិ និងធនធានរុក្ខជាតិនៅក្នុងមូលដ្ឋានសាមី។

៥-បំពេញភារកិច្ចផ្សេងទៀតក្នុងក្របខណ្ឌនៃប្រព័ន្ធវិធានការការពាររុក្ខជាតិ និងធនធានរុក្ខជាតិ។

## មាត្រា១៦.-

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត អាចស្នើសុំជំនួយអន្តរាគមន៍កម្ចាត់សមាសភាពចង្រៃពីអង្គភាពជាតិការពាររុក្ខជាតិនៃអគ្គនាយកដ្ឋានកសិកម្ម ក្នុងករណីដែលមន្ទីរសាមីមិនអាចគ្រប់គ្រងស្ថានភាពសមាសភាពចង្រៃបាន។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត មានភារកិច្ចរាយការណ៍ជូនអគ្គនាយកដ្ឋានកសិកម្មនូវស្ថានភាពអនុវត្តផែនការសកម្មភាពការពាររុក្ខជាតិប្រចាំឆ្នាំស្ថានភាពបំផ្លាញ និងលទ្ធផលកម្ចាត់សមាសភាពចង្រៃលើករណីកើតហេតុនីមួយៗប្រចាំរដូវដាំដុះ និងប្រចាំឆ្នាំ ព្រមទាំងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងសុខភាពរុក្ខជាតិ និងផលិតផលដំណាំ ព្រមទាំងធនធានរុក្ខជាតិ នៅក្នុងដែនសមត្ថកិច្ចសាមី។

## មាត្រា១៧.-

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលកាន់កាប់កសិដ្ឋានឬម្ចាស់ធនធានរុក្ខជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចដូចខាងក្រោម៖

-ត្រួតពិនិត្យតាមដានជាប្រចាំនូវវត្តមាន និងស្ថានភាពសមាសភាពចង្រៃដែលអាចបំផ្លាញធនធានរុក្ខជាតិនៅក្នុងកសិដ្ឋានរបស់ខ្លួន ដោយត្រូវចាត់វិធានការកម្ចាត់សមាសភាពចង្រៃប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពឬត្រូវទប់ស្កាត់ការរាលដាលឆ្លងឬការរាតត្បាតដល់ធនធានរុក្ខជាតិរបស់កម្មសិទ្ធករដទៃទៀត

-ត្រូវរាយការណ៍ជាបន្ទាន់ដល់អង្គភាពការពាររុក្ខជាតិដែលនៅជិតបំផុត ក្នុងករណីពិនិត្យឃើញមានវត្តមានសមាសភាពចង្រៃ ដែលកំពុងរាលដាលឆ្លងឬបំផ្លាញធ្ងន់ធ្ងរដល់ធនធានរុក្ខជាតិ ដើម្បីស្នើសុំអន្តរាគមន៍ទប់ស្កាត់ឬកម្ចាត់សមាសភាពចង្រៃឱ្យបានទាន់ពេល វេលា។

កាតព្វកិច្ចរបស់ម្ចាស់ធនធានរុក្ខជាតិក្នុងការអនុវត្តវិធានការការពាររុក្ខជាតិ ត្រូវកំណត់ដោយគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា១៨.-

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ដោយសម្របសម្រួលជាមួយអគ្គនាយកដ្ឋានកសិកម្ម ត្រូវតាមដាន វាយតម្លៃ និងរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីស្ថានភាពរាតត្បាតរបស់សមាសភាពចង្រៃនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមលក្ខខណ្ឌសម្រាប់ប្រកាសការផ្ទុះឡើងសមាសភាពចង្រៃ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសកំណត់តំបន់ផ្ទុះឡើងនូវសមាសភាពចង្រៃ តាមសំណើរបស់អគ្គនាយកដ្ឋានកសិកម្ម។

ក្នុងករណីស្ថានភាពផ្ទុះឡើងសមាសភាពចង្រៃមានកម្រិតធ្ងន់ធ្ងរ អគ្គនាយកដ្ឋានកសិកម្មត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាករណីគ្រោះបន្ទាន់នៃការ ផ្ទុះឡើងសមាសភាពចង្រៃ ដើម្បីផ្តល់មធ្យោបាយ និងធនធានចាំបាច់ សម្រាប់ការចាត់វិធានការកម្ចាត់សមាសភាពចង្រៃនៃករណីគ្រោះបន្ទាន់នេះ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។

លក្ខខណ្ឌសម្រាប់ការប្រកាស និងសិទ្ធិចាត់វិធានការចំពោះការផ្ទុះឡើងសមាសភាពចង្រៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា១៩.-

ដើម្បីទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃទៅកាន់តំបន់ផ្សេងទៀត ការដឹកជញ្ជូនរុក្ខជាតិ និងផលិតផលរុក្ខជាតិ ឆ្លងកាត់ ឬចេញពីតំបន់ដែលបានប្រកាសជាតំបន់ផ្ទុះឡើងនូវសមាសភាពចង្រៃ ត្រូវផ្អាកជាបណ្តោះអាសន្ន និងត្រូវដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពជាតិការពាររុក្ខជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរហូតដល់ពេលមានប្រកាសលុបចោលតំបន់ផ្ទុះឡើងនូវសមាសភាពចង្រៃនោះ។

អាជ្ញាធរដែនដីគ្រប់ថ្នាក់នៃតំបន់ផ្ទុះឡើងសមាសភាពចង្រៃ ត្រូវបំផុសចលនាមហាជននៅក្រោមដែនសមត្ថកិច្ចសាមី ដើម្បីប្រមូលកម្លាំងរួម និងសម្ភារសម្រាប់ការជំរុញសកម្មភាពកម្ចាត់ និងទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃ។

ក្នុងករណីស្ថានភាពផ្ទុះឡើងសមាសភាពចង្រៃមានកម្រិតធ្ងន់ធ្ងរ អាជ្ញាធរដែនដីសាមី ត្រូវជូនដំណឹងដោយផ្ទាល់ជាការប្រញាប់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវផ្តល់ព័ត៌មានឱ្យអង្គភាពជាតិការពាររុក្ខជាតិដែលនៅជិតបំផុត ដើម្បីសហការអនុវត្តវិធានការ ជាបន្ទាន់។

**មាត្រា២០.-**

ក្រោយពេលប្រកាសពីការផ្ទុះឡើងនូវសមាសភាពចង្រៃ ក្នុងករណីការរាតត្បាតត្រូវបានគ្រប់គ្រង និងលុបបំបាត់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាស ស្តីពីការលុបចោលនូវតំបន់ផ្ទុះឡើងសមាសភាពចង្រៃនោះវិញ។

**មាត្រា២១.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានវិជ្ជាជីវៈជំនាញដែលបានទទួលស្គាល់ស្របតាមច្បាប់ជាធរមានមានសិទ្ធិស្នើសុំផ្តល់សេវាកម្មការពាររុក្ខជាតិ ឬធ្វើអន្តរាគមន៍ពាក់ព័ន្ធវិធានការការពាររុក្ខជាតិដូចខាងក្រោម៖

១-ធ្វើអង្កេតស្ថានភាពសមាសភាពចង្រៃបំផ្លាញផលិតផលដំណាំឬផលិតផលរុក្ខជាតិ។

២-ផ្តល់សេវាកម្មប្រឹក្សាយោបល់លើវត្តមាន និងស្ថានភាពយាយីដែលបង្កដោយសមាសភាពចង្រៃមកលើផលិតផលដំណាំឬផលិតផលរុក្ខជាតិ។

៣-ផ្តល់ការប្រឹក្សាយោបល់ដល់ម្ចាស់កសិដ្ឋាន នូវបណ្តាវិធានការបង្ការ និងកម្ចាត់សមាសភាពចង្រៃដែលបំផ្លាញផលិតផលដំណាំឬផលិតផលរុក្ខជាតិ របស់ខ្លួន។

៤-ផ្តល់សេវាកម្មអនុវត្តវិធានការបង្ការ និងធ្វើប្រតិបត្តិការកម្ចាត់សមាសភាពចង្រៃឬផ្គត់ផ្គង់សម្ភារឧបករណ៍ និងផលិតផលការពាររុក្ខជាតិ សម្រាប់ការប្រើប្រាស់នៅក្នុងការអនុវត្តវិធានការការពាររុក្ខជាតិ ។

**មាត្រា២២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលផ្តល់សេវាកម្មក្នុងក្របខណ្ឌនៃវិធានការការពាររុក្ខជាតិ ត្រូវមានលិខិតអនុញ្ញាត ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្ម និងត្រូវបំពេញលក្ខខណ្ឌតម្រូវស្របតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ។

នីតិវិធីនិងលក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងសេវាកម្មការពាររុក្ខជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ផ្នែកទី៣
## វិធានការទប់ស្កាត់ផលប៉ះពាល់ពីការការពាររុក្ខជាតិ
## និងធនធានរុក្ខជាតិ

### មាត្រា២៣.-

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលអនុវត្តវិធានការការពាររុក្ខជាតិ ឬធ្វើប្រតិបត្តិការកម្ចាត់សមាសភាពចង្រៃ ត្រូវគោរពតាមបទបញ្ញាបច្ចេកទេសចម្បងៗ ក្នុងការអនុវត្ត វិធានការទប់ស្កាត់ផលប៉ះពាល់ពីការការពាររុក្ខជាតិ និងធនធានរុក្ខជាតិ ដូចខាងក្រោម៖

-ធានាសុវត្ថិភាពចំពោះសុខភាពរុក្ខជាតិឬដំណាំដែលត្រូវការពារ ដោយមិនប៉ះពាល់ដល់សក្តានុពលផលិតភាពឬទិន្នផលដំណាំ

-ធានាសុវត្ថិភាពពីហានិភ័យគ្រោះថ្នាក់ ចំពោះមនុស្ស សត្វ និងប្រព័ន្ធអេកូឡូស៊ីបរិស្ថានជុំវិញតំបន់ដែលអនុវត្តវិធានការ

-ធានាសុវត្ថិភាពផលិតផលដំណាំឬផលិតផលរុក្ខជាតិ ក្នុងការយកទៅប្រើប្រាស់ជាអាហារសម្រាប់មនុស្ស សត្វ ឬជាវត្ថុធាតុដើមសម្រាប់កែច្នៃ

-ធានាមិនបង្កឱ្យកើតឡើងនូវឯកត្តៈនៃប្រភេទសមាសភាពចង្រៃ ដែលមានភាពធន់ចំពោះវិធានការការពាររុក្ខជាតិ។

បទបញ្ញាបច្ចេកទេសសម្រាប់វិធានការទប់ស្កាត់ផលប៉ះពាល់ពីការការពាររុក្ខជាតិ និងធនធានរុក្ខជាតិ ត្រូវកំណត់ដោយគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### មាត្រា២៤.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់ស្តង់ដារនៃប្រព័ន្ធផលិតកម្មកសិកម្មដែលធានាសុវត្ថិភាពស្បៀង រួមមាន៖ ការអនុវត្តកសិកម្មល្អ កសិកម្មសរីរាង្គ ឬកសិកម្មគ្មានសារធាតុគីមី។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវគ្រប់គ្រងដំណើរការតាមដាន និងអនុវត្តប្រព័ន្ធផលិតកម្មកសិកម្មដែលធានាសុវត្ថិភាពស្បៀង រួមជាមួយការធ្វើវិញ្ញាបនកម្មលើផលិតផលដំណាំឬផលិតផលរុក្ខជាតិ។

ការគ្រប់គ្រងប្រព័ន្ធផលិតកម្មកសិកម្មដែលធានាសុវត្ថិភាពស្បៀង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលអនុវត្តវិធានការការពាររុក្ខជាតិ ឬធ្វើប្រតិបត្តិការកម្ចាត់សមាសភាពចង្រៃ នៅក្នុងផលិតកម្មដំណាំ មានកាតព្វកិច្ចចូលរួមធានាសុវត្ថិភាពស្បៀង និងផលិតផលដំណាំជាចាំបាច់។

ផលិតផលដំណាំ ដែលប្រមូលផលចេញពីកន្លែងដាំដុះ ក្នុងគោលបំណងធ្វើចរាចរណ៍ទីផ្សារ ឬប្រើប្រាស់ជាអាហារសម្រាប់មនុស្ស ចំណីសត្វ ឬជាវត្ថុធាតុដើមក្នុងការកែច្នៃជាអាហារ ត្រូវធានាបាននូវសុវត្ថិភាពស្បៀងគ្មានសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព ទោះសារធាតុជីវសាស្ត្រឬសារធាតុគីមីក្តី ឬមានសមាសភាគនៃសំណល់ថ្នាំកសិកម្ម ស្ថិតក្រោមកម្រិតអតិបរិមា ដែលកំណត់ដោយស្តង់ដារជាតិ ឬស្តង់ដារបង្អែកណាមួយ ដែលបានទទួលស្គាល់និងប្រើប្រាស់ក្នុងតំបន់ឬអន្តរជាតិ ឬស្របតាមស្តង់ដារតម្រូវរបស់ប្រទេសនាំចូលក្នុងករណីផលិតផលដំណាំឬផលិតផលរុក្ខជាតិនោះ ត្រូវនាំចេញសម្រាប់ប្រើប្រាស់ជាអាហារ។

កម្រិតសំណល់អតិបរមានៃថ្នាំកសិកម្ម និងសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព នៅក្នុងកសិផលមានដើមកំណើតពីរុក្ខជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២៦.-**

អគ្គនាយកដ្ឋានកសិកម្មមានសមត្ថកិច្ចត្រួតពិនិត្យកម្រិតសំណល់អតិបរមានៃថ្នាំកសិកម្ម និងសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព នៅក្នុងកសិផលមានដើមកំណើតពីរុក្ខជាតិ ដែលត្រូវនាំចេញ ឬត្រូវនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅមុនពេលដែលផលិតផលទាំងនេះត្រូវធ្វើពាណិជ្ជកម្ម ផ្គត់ផ្គង់ចែកចាយ ឬធ្វើចរាចរណ៍នៅលើទីផ្សារ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំនិងបង្កើតទីកន្លែងប្រមូលផ្តុំកសិផលមានដើមកំណើតពីរុក្ខជាតិ នៅរាជធានី ខេត្ត សម្រាប់ការត្រួតពិនិត្យកម្រិតអតិបរមានៃសំណល់ថ្នាំកសិកម្ម និងសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព នៅមុនពេលដែលផលិតផលទាំងនោះ ត្រូវបានអនុញ្ញាតឱ្យផ្គត់ផ្គង់ចែកចាយដល់អ្នកប្រើប្រាស់ ឬធ្វើចរាចរណ៍នៅលើទីផ្សារ។

ការបង្កើត និងការគ្រប់គ្រងទីកន្លែងប្រមូលផ្តុំកសិផលមានដើមកំណើតពីរុក្ខជាតិ នៅរាជធានី ខេត្ត សម្រាប់ការត្រួតពិនិត្យកម្រិតអតិបរមានៃសំណល់ថ្នាំកសិកម្ម និងសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២៧.-**

ត្រូវហាមឃាត់ចំពោះសកម្មភាពពាក់ព័ន្ធ ដូចខាងក្រោម៖

១-ប្រតិបត្តិការការពាររុក្ខជាតិដែលងាយបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ សត្រូវធម្មជាតិ និង ប្រព័ន្ធអេកូឡូស៊ីបរិស្ថានដោយផ្ទុយនឹងបទបញ្ជាបច្ចេកទេសសម្រាប់វិធានការទប់ស្កាត់ផលប៉ះពាល់ពីការការពាររុក្ខជាតិ និងធនធានរុក្ខជាតិ។

២-ការប្រើប្រាស់ផលិតផលការពាររុក្ខជាតិ ឬសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព ទោះជាផលិតផលដែលលាយផ្សំដោយសារធាតុគីមី ឬជីវសាស្ត្រក្តី ទៅលើផលិតផលដំណាំឬផលិតផលរុក្ខជាតិ ដែលត្រៀមបម្រុងដើម្បីផ្គត់ផ្គង់ចែកចាយ ដាក់តាំងលក់ ឬធ្វើចរាចរណ៍នៅលើទីផ្សារសម្រាប់ប្រើប្រាស់ជាអាហាររបស់មនុស្សឬជាចំណីសត្វ។

៣-ការនាំយកកសិផលមានដើមកំណើតពីរុក្ខជាតិ ដែលមានសំណល់ផលិតផលការពាររុក្ខជាតិ ឬសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព លើសកម្រិតអតិបរមាកំណត់ ដើម្បីផ្គត់ផ្គង់ចែកចាយ ដាក់តាំងលក់ឬធ្វើចរាចរណ៍នៅលើទីផ្សារសម្រាប់ប្រើប្រាស់ជាអាហាររបស់មនុស្សឬជាចំណីសត្វ។

៤-ការនាំចេញ ការនាំចូល ការរក្សាទុក ការដឹកជញ្ជូន ការតាំងលក់ និងការប្រើប្រាស់ពូជដំណាំ ដែលមានចម្លងសមាសភាពចង្រៃក្នុងកម្រិតធ្ងន់ធ្ងរ ឬមានចម្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃជាប់បញ្ញត្តិ។

## ជំពូកទី៤
## ការត្រួតពិនិត្យភូតគាមអនាម័យ
### ផ្នែកទី១
### វិធានរួមនៃការត្រួតពិនិត្យភូតគាមអនាម័យ

**មាត្រា២៨.-**

វិធានការភូតគាមអនាម័យត្រូវអនុវត្តក្នុងគោលបំណងទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ សមាសភាពចង្រៃមិនមែនភូតគាមអនាម័យជាប់បញ្ញត្តិពីប្រទេសមួយទៅប្រទេសមួយ និងពីតំបន់មួយទៅតំបន់មួយ ព្រមទាំងធានាសុវត្ថិភាពកសិផលមានដើមកំណើតពីរុក្ខជាតិចំពោះកម្រិតសំណល់អតិបរមានៃថ្នាំកសិកម្ម និងសារធាតុបង្កប៉ះពាល់ចំពោះសុខភាព ប៉ុន្តែមិនត្រូវដាក់កំហិតលើសពីលក្ខខណ្ឌតម្រូវចាំបាច់ចំពោះសកម្មភាពពាណិជ្ជកម្មឡើយ។

គោលការណ៍នៃវិធានការភូតគាមអនាម័យ ត្រូវអនុវត្តដោយអនុលោមតាមៈ

-ស្តង់ដារអន្តរជាតិស្តីពីវិធានការភូតគាមអនាម័យ ដែលអនុម័តដោយអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ

-លក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល

-លក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា២៩.-

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិ ត្រូវបំពេញសមត្ថកិច្ចជាអចិន្ត្រៃយ៍ដើម្បីត្រួតពិនិត្យ និងអនុវត្តវិធានការភូតគាមអនាម័យនៅការិយាល័យសាខាភូតគាមអនាម័យប្រចាំតំបន់ ស្ថានីយភូតគាមចត្តាឡីសក័ និងនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យនៅច្រកទ្វារអន្តរជាតិច្រកទ្វារព្រំដែនគ្រប់ប្រភេទ នៅអាកាសយានដ្ឋាន ស្ថានីយរថភ្លើង ចំណតរថយន្តផ្ទុកទំនិញ កំពង់ផែគ្រប់ប្រភេទ នៅគ្រឹះស្ថានប្រៃសណីយ៍ ឬគ្រឹះស្ថានចែកចាយទំនិញបញ្ញើ ឬនៅទីកន្លែងដែលចាំបាច់ តាមចំនួន និងទីតាំងសមស្របដើម្បីអនុវត្តវិធានការភូតគាមអនាម័យ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

រាជរដ្ឋាភិបាលគាំទ្រ ការពង្រឹងសមត្ថភាព និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសសមស្រប របស់ការិយាល័យសាខាភូតគាមអនាម័យប្រចាំតំបន់ ស្ថានីយភូតគាមចត្តាឡីសក័ និងស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យតាមច្រកទ្វារព្រំដែនគ្រប់ប្រភេទ

ដែលអាចធានាបាននូវការបំពេញសមត្ថកិច្ចរបស់អង្គភាពជាតិការពាររុក្ខជាតិ ស្របតាមការកំណត់របស់ស្តង់ដារអន្តរជាតិនៃវិធានការភូតគាមអនាម័យ។

**មាត្រា៣០.-**

ក្រោមគោលបំណងនៃការត្រួតពិនិត្យភូតគាមអនាម័យ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិ បំពេញសមត្ថកិច្ច ដូចខាងក្រោម៖

១-ត្រួតពិនិត្យរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀតដែលកំពុងតែដាំដុះ រក្សាទុកក្នុងឃ្លាំង ឬកំពុងដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ដើម្បីរាយការណ៍ពីស្ថានភាពនៃការបង្ក ការផ្ទុះឡើង ឬការរាលដាលឆ្លងនៃសមាសភាពចង្រៃភូតគាមអនាម័យដែលត្រូវហាមឃាត់។

២-ត្រួតពិនិត្យការដឹកជញ្ជូន ឬទំនិញបញ្ញើរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ដែលត្រូវនាំចូល នាំចេញ ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណត់ផលប៉ះពាល់និងចាំបាច់ត្រូវបញ្ជាក់ពីស្ថានភាពសមាសភាពចង្រៃនៃទំនិញបញ្ញើ ដែលបានបញ្ជូនតាមរយៈការដកយកសំណាកដើម្បីវិភាគ
ហានិភ័យសមាសភាពចង្រៃ។

៣-ត្រួតពិនិត្យកម្រិតសំណល់អតិបរមានៃថ្នាំកសិកម្ម
និងសារធាតុបង្កផលប៉ះពាល់ចំពោះសុខភាព នៅក្នុងកសិផលមានដើមកំណើតពីរុក្ខជាតិដែលត្រូវនាំចេញឬត្រូវនាំចូល
ស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា។

៤-ត្រូវធានាចំពោះទំនិញ ព្រមទាំងសម្ភារវេចខ្ចប់ទំនិញគ្រប់ប្រភេទ ទីកន្លែងសន្និធិទំនិញ មធ្យោបាយដឹកជញ្ជូន និងផ្ទុកទំនិញ ដែលត្រូវនាំចូល នាំចេញ ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានរម្ងាប់សមាសភាពចង្រៃ។

៥-ត្រូវធានាចំពោះ សំណល់ដែលត្រូវបោះចោលបានមកពី៖ ជើងហោះហើរដែលមកដល់ព្រះរាជាណាចក្រកម្ពុជា និងទីកន្លែងដែលកែច្នៃ ឬលាងសម្អាតរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ដែលបានធ្វើការនាំចូលមិនបណ្តាលឱ្យមានការគំរាមកំហែងចំពោះធនធានរុក្ខជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

៦-ទទួលពាក្យស្នើសុំត្រួតពិនិត្យភូតគាមអនាម័យ ដោយត្រូវពិនិត្យផ្ទៀងផ្ទាត់ឯកសារពាក់ព័ន្ធភ្ជាប់ពាក្យស្នើសុំវាយតម្លៃហានិភ័យសមាសភាពចង្រៃ
ផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យនាំចូល ឬផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ

សម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជានូវរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត។

៧-អង្កេតតាមដាន និងធ្វើបច្ចុប្បន្នភាពនូវព័ត៌មានស្តីពីស្ថានភាពសមាសភាពចង្រៃក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវផ្លាស់ប្តូរព័ត៌មានទាំងនេះជាប្រចាំជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតាមបណ្តាខេត្ត រាជធានី នៅការិយាល័យសាខាភូតគាមអនាម័យប្រចាំតំបន់ ឬនៅស្ថានីយភូតគាមចត្តាឡីសក័ និងទីកន្លែងបំពេញសមត្ថកិច្ចផ្សេងទៀត។

៨-ស្រាវជ្រាវ និងស្នើសុំព័ត៌មានឬឯកសារពាក់ព័ន្ធ នៅពេលកើតមានករណីសង្ស័យដែលរំលោភលើលក្ខខណ្ឌតម្រូវភូតគាមអនាម័យ ដូចមានចែងក្នុងច្បាប់នេះ។ នៅពេលចាំបាច់ត្រូវអនុវត្តវិធានការក្រោយពេលត្រួតពិនិត្យ ដើម្បីតាមដានសន្តិសុខភូតគាមអនាម័យស្របតាមនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ។

៩-បំពេញសមត្ថកិច្ចផ្សេងទៀតក្នុងក្របខណ្ឌនៃការត្រួតពិនិត្យ និងការអនុវត្តវិធានការភូតគាមអនាម័យ។

**មាត្រា៣១.-**

នាយកដ្ឋានការពារដំណាំ អនាម័យ និង ភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិ មានសិទ្ធិបដិសេធ ឬចាត់វិធានការក្នុងក្របខណ្ឌនៃការត្រួតពិនិត្យលើទំនិញ ជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដូចខាងក្រោម៖

១-មិនអនុញ្ញាតឱ្យនាំចូល នាំចេញ ឬដឹកជញ្ជូនឆ្លងកាត់ នូវរាល់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលមិនបានឆ្លើយតបចំពោះវិធាននិងលក្ខខណ្ឌតម្រូវភូតគាមអនាម័យ ដូចមានចែងក្នុងច្បាប់នេះ។

២-បដិសេធការនាំចេញនូវរាល់ទំនិញបញ្ញើ ដែលមិនគោរពតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល។

៣-ប្រកាសអសុពលភាពចំពោះវិញ្ញាបនបត្រភូតគាមអនាម័យ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសផ្សេងទៀត ក្នុងករណីបានត្រួតពិនិត្យឃើញវត្តមាននៃសមាសភាពចង្រៃ ឬសញ្ញាកាយបង្គគ្រោះថ្នាក់នៅលើទំនិញបញ្ញើ។

ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣២.–**

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ជាអង្គភាពជាតិការពាររុក្ខជាតិ ត្រូវផ្ដល់វិញ្ញាបនបត្រភូតគាមអនាម័យនាំចូល ឬផ្ដល់វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញ ឬសម្រាប់ការនាំចេញបន្តពីព្រះរាជាណាចក្រកម្ពុជានូវរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ស្របតាមគំរូវិញ្ញាបនបត្រដែលប្រើប្រាស់ជាសកល ក្រោមអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ។

ក្នុងករណីវិញ្ញាបនបត្រភូតគាមអនាម័យត្រូវបានបាត់ ឬខូចខាតដោយមូលហេតុជាក់លាក់ណាមួយនៅក្នុងរយៈពេលសុពលភាព ប្រតិបត្តិករនាំចូលឬនាំចេញត្រូវរាយការណ៍ និងស្នើសុំអគ្គនាយកដ្ឋានកសិកម្ម ដើម្បីចេញវិញ្ញាបនបត្រភូតគាមអនាម័យជំនួស ឬវិញ្ញាបនបត្រ "ច្បាប់ចម្លងតាម"។

**មាត្រា៣៣.–**

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ជាអង្គភាពជាតិការពាររុក្ខជាតិ និងការិយាល័យសាខាភូតគាមអនាម័យប្រចាំតំបន់នៃអគ្គនាយកដ្ឋានកសិកម្ម មានសិទ្ធិប្រើប្រាស់ត្រាភូតគាមអនាម័យ សម្រាប់វាយសម្គាល់លើវិញ្ញាបនបត្រភូតគាមអនាម័យ ដែលត្រូវចេញសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម រុក្ខជាតិ ផលិតផលរុក្ខជាតិ និង ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ស្របតាមច្បាប់នេះ។

សិទ្ធិប្រើប្រាស់ និងគំរូត្រាភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣៤.–**

ក្នុងក្របខណ្ឌនៃសមាហរណកម្មតំបន់ និងអន្តរជាតិ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិត្រូវជំរុញការអនុវត្តវិញ្ញាបនកម្មភូតគាមអនាម័យអេឡិចត្រូនិច នៅក្នុងនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យចំពោះទំនិញនាំចូល នាំចេញ ឬនាំចេញបន្ត។

នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យដែលជាអង្គភាពជាតិការពាររុក្ខជាតិ មានសិទ្ធិអនុវត្តការត្រួតពិនិត្យភូតគាមអនាម័យចំពោះប្រតិបត្តិករដែលធ្វើសេចក្ដីប្រកាសតា

មរយៈអេឡិចត្រូនិចអំពីទំនិញរបស់ខ្លួន ថាបាន "គោរពតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យ" ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់នេះ។

នីតិវិធីនិងលក្ខខណ្ឌតម្រូវសម្រាប់ការអនុវត្តវិញ្ញាបនកម្មភូតគាមអនាម័យអេឡិចត្រូនិច ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា៣៥.-

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យដែលជាអង្គភាពជាតិការពាររុក្ខជាតិ ត្រូវគ្រប់គ្រងប្រព័ន្ធមូលដ្ឋានទិន្នន័យភូតគាមអនាម័យ តាមរយៈការតភ្ជាប់បណ្ដាញការងាររបស់អង្គភាពជាតិការពាររុក្ខជាតិ ដែលបំពេញសមត្ថកិច្ចតាមបណ្ដាទីកន្លែងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើតជា"**បញ្ជីរជាតិភូតគាមអនាម័យ**"។

ការបង្កើតបញ្ជីរជាតិភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# ផ្នែកទី២
# ការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ

## មាត្រា៣៦.-

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិ ត្រូវអនុវត្តការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ ចំពោះរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ដែលបម្រុងធ្វើការនាំចូល។

ការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ ត្រូវអនុវត្តនៅពេលស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចូល ឬនៅមុនពេលនាំចូលទំនិញ ដើម្បីកំណត់រកមុខសញ្ញាសមាសភាពចង្រៃដែលអាចបង្កហានិភ័យ និងកំណត់វិធានការគ្រប់គ្រងសមាសភាពចង្រៃនៅពេលនាំចូល។

## មាត្រា៣៧.-

ក្នុងករណីចាំបាច់ ឬនៅពេលមានការអញ្ជើញពីប្រទេសនាំចេញណាមួយដើម្បីបំពេញសមត្ថកិច្ចត្រួតពិនិត្យភូតគា

មអនាម័យ
ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិអាចអនុវត្តការធ្វើវិភាគហានិភ័យសមាសភាពចង្រៃលើផលិតផលបម្រុងនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើការត្រួតពិនិត្យភូតគាមអនាម័យ និងធ្វើវិញ្ញាបនកម្មរួមគ្នានៅលើដែនដីនៃប្រទេសនាំចេញដោយផ្ទាល់ ស្របតាមលក្ខខណ្ឌតម្រូវដែលបានព្រមព្រៀង។

រដ្ឋភាគីនៃប្រទេសនាំចេញ ត្រូវទទួលបន្ទុករាល់ចំណាយ នៅក្នុងដំណើរការធ្វើវិភាគហានិភ័យសមាសភាពចង្រៃលើផលិតផលបម្រុងនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៨.-**

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិ អាចអនុវត្តការធ្វើវិភាគហានិភ័យសមាសភាពចង្រៃលើផលិតផលបម្រុងនាំចេញពី
ព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមលក្ខខណ្ឌតម្រូវរបស់ភាគីប្រទេសនាំចូល ឬតាមរយៈលិខិតុបករណ៍ព្រមព្រៀងគ្នារវាងរដ្ឋភាគីនាំចូល និងរដ្ឋភាគីនាំចេញ។

ក្នុងករណីចាំបាច់
រដ្ឋភាគីនៃប្រទេសនាំចូលអាចអនុវត្តការធ្វើវិភាគហានិភ័យសមាសភាពចង្រៃលើផលិតផលបម្រុងនាំចេញពីព្រះរាជាណាចក្រកម្ពុជា នៅព្រះរាជាណាចក្រកម្ពុជាដោយផ្ទាល់ស្របតាមលក្ខខណ្ឌតម្រូវដែលបានព្រមព្រៀង។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគីនៃប្រទេសនាំចេញ ត្រូវទទួលបន្ទុករាល់ចំណាយ នៅក្នុងដំណើរការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ
លើផលិតផលបម្រុងនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៩.-**

នីតិវិធីក្នុងការធ្វើវិភាគហានិភ័យសមាសភាពចង្រៃលើផលិតផលបម្រុងនាំចូល ឬនាំចេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី៣
## ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូល

**មាត្រា៤០.-**

ក្នុងគោលបំណងទប់ស្កាត់ការបង្ក និងការរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ អគ្គនាយកដ្ឋានកសិកម្ម ត្រូវកំណត់លក្ខខណ្ឌតម្រូវភូតគាមអនាម័យនិងវិធានការភូតគាមអនាម័យ លើការនាំចូលរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដោយផ្អែកតាមស្តង់ដារ ឬសុវិធានបច្ចេកទេសអន្តរជាតិជាធរមាន។

យោងតាមលក្ខខណ្ឌផ្លាស់ប្តូរឬស្ថានការណ៍ថ្មីកើតមានឡើង អគ្គនាយកដ្ឋានកសិកម្ម អាចកែសម្រួលឬដកចេញនូវលក្ខខណ្ឌតម្រូវភូតគាមអនាម័យ និងវិធានការភូតគាមអនាម័យព្រមទាំងការហាមឃាត់លើការនាំចូល ជាការចាំបាច់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចវាយតម្លៃ និងទទួលយកវិធានការភូតគាមអនាម័យជំនួស ដែលស្នើដោយអង្គភាពជាតិការពាររុក្ខជាតិនៃប្រទេសនាំចេញ ដែលមានតម្លៃសមមូលចំពោះវិធានការភូតគាមអនាម័យ ដែលតម្រូវក្រោមកថាខណ្ឌទី១នៃមាត្រានេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចុះផ្សាយជាផ្លូវការនូវលក្ខខណ្ឌតម្រូវភូតគាមអនាម័យ ការហាមឃាត់ និងការកែប្រែទាំងឡាយក្រោមមាត្រានេះ។

**មាត្រា៤១.-**

នៅមុនពេលធ្វើប្រតិបត្តិការនាំចូលទំនិញជារុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យនាំចូល នៅអង្គភាពជាតិការពាររុក្ខជាតិនៃអគ្គនាយកដ្ឋានកសិកម្មដោយត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធទំនិញដែលត្រូវនាំចូល និងត្រូវបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូល។

ការវាយតម្លៃលើពាក្យស្នើសុំ ត្រូវអនុលោមតាមស្តង់ដារអន្តរជាតិដែលមានស្រាប់ និងត្រូវអនុវត្តការវិភាគហានិភ័យសមាសភាពចង្រៃ ដើម្បីកំណត់លក្ខខណ្ឌតម្រូវភូតគាមអនាម័យ ដែលត្រូវអនុវត្តលើទំនិញទាំងនោះ។

**មាត្រា៤២.-**

រូបវន្តបុគ្គលឬនីតិបុគ្គល អាចនាំចូលទំនិញបញ្ញើមកក្នុងព្រះរាជាណាចក្រកម្ពុជាបានដោយត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ត្រូវមានវិញ្ញាបនបត្រភូតគាមអនាម័យនាំចូល ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្ម ហើយប្រតិបត្តិករត្រូវបំពេញលក្ខខណ្ឌគ្រប់គ្រាន់ រួមជាមួយការបង់កម្រៃសេវាសាធារណៈពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

២-ត្រូវមានវិញ្ញាបនប័ត្រភូតគាមអនាម័យច្បាប់ដើម ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ នៅមុនពេលដែលទំនិញត្រូវបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-
ត្រូវមានភ្ជាប់ជាមួយនូវវិញ្ញាបនបត្របញ្ជាក់ការធ្វើប្រព្រឹត្តិកម្មឬធូបទកម្មលើទំនិញបញ្ញើ ក្នុងករណីបានអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ ឬឯកសារពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

៤-ត្រូវធ្វើការនាំចូលនូវទំនិញរបស់ខ្លួនតាមមាត់ច្រកដែលបានអនុញ្ញាត នៅក្នុងវិញ្ញាបនបត្រភូតគាមអនាម័យនាំចូល។

៥-
ត្រូវរាយការណ៍ជូនភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យនៅមាត់ច្រកនាំចូលសាមី អំពីការមកដល់នូវទំនិញបញ្ញើរបស់ខ្លួន ដើម្បីស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យ។

**មាត្រា៤៣.-**

មន្ត្រីមានសមត្ថកិច្ចនៃអង្គភាពគយ និងរដ្ឋាករកម្ពុជា និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធប្រចាំមាត់ច្រកព្រំដែន ឬច្រកទ្វារនាំចូលគ្រប់ប្រភេទនៃអាកាសយានដ្ឋាន កំពង់ផែគ្រប់ប្រភេទស្ថានីយរថភ្លើង ចំណតរថយន្តដឹកជញ្ជូន ព្រមទាំងភ្នាក់ងារប្រៃសណីយ៍ទូរគមនាគមន៍ ឬភ្នាក់ងារចែកចាយទំនិញបញ្ញើដែលពាក់ព័ន្ធ នៅពេលបានទទួលសេចក្តីប្រកាសអំពីទំនិញនាំចូល ឬមានការស្នើសុំត្រួតពិនិត្យភូតគាមអនាម័យដោយប្រតិបត្តិករនាំចូល ឬបានដឹងអំពីការមកដល់នូវទំនិញជារុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យ
ភូតគាមអនាម័យផ្សេងទៀត
មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធទាំងនោះមានភារកិច្ចជូនព័ត៌មានឱ្យមន្ត្រីភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចប្រចាំការនៅស្នាក់ការត្រួតពិនិត្យភូត
គាមអនាម័យនៃមាត់ច្រកសាមី ដើម្បីបំពេញសមត្ថកិច្ចត្រួតពិនិត្យភូតគាមអនាម័យ។

មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធខាងលើត្រូវឃាត់ទុកទំនិញទាំងនោះនៅចំណុចសូន្យនៃកំពង់ផែសាមី នៅក្នុងឃ្លាំងឬនៅទីលានសន្និធិទំនិញនៃច្រកទ្វារនាំចូលសាមីទាំងព្រំដែនគោក ព្រំដែនទឹក និងដែនអាកាស ដើម្បីរួមជាមួយមន្ត្រីភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ ធ្វើការត្រួតពិនិត្យ និងអនុវត្តនីតិវិធីភូតគាមអនាម័យ ស្របតាមសមត្ថកិច្ចជំនាញ។

**មាត្រា៤៤.-**

ក្រោមគោលបំណងនៃកិច្ចសម្រួលពាណិជ្ជកម្ម និងក្នុងករណីចាំបាច់ជាក់ស្តែង ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច មានសិទ្ធិជ្រើសរើសទីតាំងសមស្របផ្សេងពីទីតាំងមាត់ច្រកព្រំដែន ដើម្បីបំពេញសមត្ថកិច្ចត្រួតពិនិត្យភូតគាមអនាម័យ នៅកន្លែងចេញដំណើរ ឬកន្លែងមកដល់របស់អ្នកដំណើរ នៅឃ្លាំងបញ្ចេញទំនិញរបស់អង្គភាពគយ និងរដ្ឋាករ ឬនៅក្នុង
ឃ្លាំងសន្និធិទំនិញផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងកាលៈទេសៈជាក់លាក់
ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យអាចលើកលែងការត្រួតពិនិត្យចំពោះរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត និងអនុញ្ញាតឱ្យនាំចូល ដោយផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម៖

១-លទ្ធផលវិភាគហានិភ័យសមាសភាពចង្រៃ ដែលបញ្ជាក់ថាមានសុវត្ថិភាព និងសន្តិសុខភូតគាមអនាម័យ ចំពោះទំនិញបញ្ញើ។

២-គុណភាពនៃទំនិញបញ្ញើត្រូវបានទទួលស្គាល់ ដោយស្តង់ដារគុណភាពអន្តរជាតិ។

៣-ប្រតិបត្តិករបានបំពេញនូវលក្ខខណ្ឌតម្រូវគ្រប់គ្រាន់ឬសមមូល
ឬបានបំពេញលក្ខខណ្ឌតម្រូវតាមរយៈសេចក្តីប្រកាសអេឡិចត្រូនិច
នូវទំនិញបញ្ញើដែលត្រូវនាំចូល។

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច
មានសិទ្ធិកំណត់រយៈពេលសុពលភាពសម្រាប់ការអនុញ្ញាតឱ្យនាំចូល ការត្រួតពិនិត្យឡើងវិញ ការដកហូតវិញ្ញាបនបត្រភូតគាមអនាម័យនាំចូល
ឬលុបចោលការអនុញ្ញាតនាំចូលនៅពេលណាមួយ តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ។

**មាត្រា៤៥.-**

ការត្រួតពិនិត្យភូតគាមអនាម័យនៅមាត់ច្រកនាំចូលត្រូវអនុវត្តនៅម៉ោងធ្វើការជាផ្លូវការ ដោយទៀងទាត់ និងត្រូវបញ្ចប់នៅក្នុងរយៈពេល២៤(ម្ភៃបួន) ម៉ោង ដោយគិតចាប់ពីពេលបានទទួលសេចក្ដីជូនដំណឹង និងការមកដល់នៃទំនិញបញ្ញើនៅចំណុចត្រួតពិនិត្យភូតគាម អនាម័យ ដែលបានកំណត់។

**មាត្រា៤៦.-**

ក្នុងករណីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យត្រូវបានបញ្ជាក់ថាទំនិញបញ្ញើ មានឯកសារអមត្រឹមត្រូវនិងគ្រប់គ្រាន់ ហើយទំនិញបញ្ញើនោះពុំមានហានិភ័យសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃភូតគាមអនាម័យបង្កគ្រោះថ្នាក់ណាមួយ មន្ត្រី ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវចេញសេចក្ដីជូនដំណឹងជាលាយ លក្ខណ៍អក្សរចំពោះមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច ដើម្បីអនុញ្ញាតឱ្យប្រតិបត្តិករធ្វើការនាំចូលទំនិញរបស់ខ្លួនមកក្នុងព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចនៅមាត់ច្រកនាំចូល អាចអនុញ្ញាតឱ្យប្រតិបត្តិករបញ្ចេញទំនិញទាំងនោះចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាបាន ក្នុងករណីប្រតិបត្តិករបានបង្ហាញសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ មានសមត្ថកិច្ចដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

**មាត្រា៤៧.-**

ក្នុងករណីប្រតិបត្តិករនាំចូលទំនិញបញ្ញើមិនបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវ ឬលទ្ធផលត្រួតពិនិត្យភូតគាមអនាម័យនៅមាត់ច្រកនាំចូល បានបង្ហាញនូវហានិភ័យនៃការរាលដាលឆ្លងសមាសភាពចង្រៃ ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវឃាត់ទុកទំនិញទាំងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូនម្ចាស់ទំនិញ ដោយបញ្ជាក់ថាផ្នែកខ្លះនៃទំនិញ ឬទំនិញទាំងមូល ត្រូវបានសម្រេចចាត់វិធានការដូចខាងក្រោម៖

១-ត្រូវអនុវត្តវិធានភូតគាមអនាម័យសមស្របដើម្បីកម្ចាត់ចោលនូវហានិភ័យ។

២-ត្រូវធ្វើការនាំចេញទៅប្រភពដើមវិញ។

៣-ត្រូវប្រកាសជាទំនិញមិនអាចលក់ចែកចាយបាន។

៤-ត្រូវឃាត់ទុកទំនិញទាំងនោះដើម្បីបំផ្លាញចោល។

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវចាត់វិធានការរក្សាទុកនូវទំនិញបញ្ញើទាំងអស់ដែលបានឃាត់ទុកក្រោមមាត្រានេះ ដើម្បីអនុវត្តវិធានការភូតគាមអនាម័យនៅក្នុងរយៈពេលមិនលើសពី៣(បី)ថ្ងៃ។

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច មានសិទ្ធិចាត់វិធានការបំផ្លាញចោលនូវទំនិញឬផ្នែកណាមួយនៃទំនិញបញ្ញើ ដែលបានរកឃើញវត្ថុមានហានិភ័យខ្ពស់ក្នុងការរាលដាលឆ្លងសមាសភាពចង្រៃ។

## មាត្រា៤៨.-

នៅក្រោយពេលទំនិញត្រូវបានអនុញ្ញាតឱ្យចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្រោយពេលបានធ្វើប្រព្រឹត្តិកម្មចំពោះទំនិញនាំចូលរួច ក្នុងករណីមានផ្នែកខ្លះនៃទំនិញត្រូវបានខូចខាតនៅក្នុងរយៈពេលដំណើរការត្រួតពិនិត្យនោះ ឬត្រូវបានរកឃើញទំនិញខ្លះដែលមិនបានធ្វើប្រតិវេទន៍ និងកំពុងប្រឈមចំពោះការខូចខាតដែលបង្កដោយសមាសភាពចង្រៃភ្នាក់ងារត្រួត ពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវចាត់វិធានការបំផ្លាញចោលជាបន្ទាន់។

រាល់ការចំណាយចំពោះដំណើរការអនុវត្តន៍វិធានការភូតគាមអនាម័យ ដូចមានចែងក្នុងមាត្រា៤៧នៃច្បាប់នេះគឺជាបន្ទុករបស់ប្រតិបត្តិករនាំចូល។

# ផ្នែកទី៤
# ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ និងទំនិញនាំចេញបន្ត

## មាត្រា៤៩.-

នៅក្នុងរយៈពេលមិនលើសពី១០(ដប់)ថ្ងៃ នៅមុនពេលធ្វើការនាំចេញពីព្រះរាជាណាចក្រកម្ពុជា នូវរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត និងដោយអនុលោមតាមលក្ខខណ្ឌភូតគាមអនាម័យរបស់ប្រទេសនាំចូលប្រតិបត្តិករនាំចេញត្រូវៈ

១-ដាក់ពាក្យស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញ ។

២-ត្រូវផ្ដល់នូវឯកសារពាក់ព័ន្ធស្របតាមលក្ខខណ្ឌតម្រូវ។

៣-រៀបចំទំនិញបញ្ញើឱ្យបានរួចជាស្រេចសម្រាប់ការត្រួតពិនិត្យភូតគាមអនាម័យ និងការធ្វើប្រព្រឹត្តិកម្ម ធូបទកម្ម ឬការធ្វើតេស្ត តាមការចាំបាច់។

៤-បង់ប្រាក់កម្រៃសេវាសាធារណៈសម្រាប់ការត្រួតពិនិត្យភូតគាមអនាម័យ ឬសម្រាប់សេវាកម្មពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៥០.-**

នៅពេលដែលទំនិញត្រូវបានដឹកជញ្ជូនចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបន្ទាប់មកត្រូវធ្វើការនាំចេញបន្តទៅប្រទេសមួយទៀត ប្រតិបត្តិករនាំចេញ ត្រូវ៖

១-ដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្រភូតគាមអនាម័យសម្រាប់ការនាំចេញបន្ត។

២-ផ្តល់នូវឯកសារទាំងឡាយ ដែលតម្រូវសម្រាប់ការនាំចេញបន្ត។

៣-បង់កម្រៃសេវាសាធារណៈសម្រាប់ការនាំចេញបន្តរួមមានការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញបញ្ញើ និងការចេញវិញ្ញាបនប័ត្រភូតគាមអនាម័យ។

៤-បង្កលក្ខណៈសម្រាប់ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញបញ្ញើ។

**មាត្រា៥១.-**

នៅពេលបានទទួលពាក្យស្នើសុំរបស់ប្រតិបត្តិករនាំចេញបន្តនូវទំនិញបញ្ញើភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្មត្រូវចាត់ការត្រួតពិនិត្យភូតគាមអនាម័យជាបន្ទាន់ ដោយមិនត្រូវពន្យារពេលឡើយ។ បន្ទាប់ពីបានត្រួតពិនិត្យភូតគាមអនាម័យជូនប្រតិបត្តិកររួច អគ្គនាយកដ្ឋានកសិកម្មត្រូវចេញវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញបន្តនូវទំនិញបញ្ញើ ដោយត្រូវបញ្ជាក់ជាចាំបាច់នូវប្រទេសប្រភពដើមនៃទំនិញបញ្ញើដែលធ្វើការដឹកជញ្ជូន និងត្រូវផ្អែកតាមហេតុផលដូចខាងក្រោម៖

១-ទំនិញបញ្ញើពុំមានសញ្ញាហានិភ័យចម្លងសមាសភាពចង្រៃឡើយ។

២-លក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូលមានលក្ខណៈប្រហាក់ប្រហែល ឬមានលក្ខខណ្ឌទាបជាងលក្ខខណ្ឌកំណត់ដោយប្រទេសនាំចេញ។

៣-បណ្តាឯកសារដែលត្រូវភ្ជាប់មានសង្គតិភាពជាមួយលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល។

**មាត្រា៥២.-**

ប្រតិបត្តិករអាចនាំចេញបន្តនូវទំនិញបញ្ញើរបស់ខ្លួនបន្ទាប់ពីបានទទួលវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញបន្តដោយអនុលោមតាមលក្ខខណ្ឌតម្រូវដែលបានកំណត់សម្រាប់ការរក្សាសន្តិសុខភូតគាមអនាម័យនៃទំនិញបញ្ញើ នៅក្រោយពេលចេញវិញ្ញាបនបត្រ ឬនៅមុនពេលធ្វើការនាំចេញបន្ត។

ប្រតិបត្តិករត្រូវប្រើប្រាស់វិញ្ញាបនបត្រភូតគាមអនាម័យច្បាប់ដើមភ្ជាប់ជាមួយដំណើរការដឹកជញ្ជូនទំនិញបញ្ញើសម្រាប់ការនាំចេញបន្ត។

## ផ្នែកទី៥
## ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់

**មាត្រា៥៣.-**

ការត្រួតពិនិត្យភូតគាមអនាម័យចំពោះរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ដែលធ្វើការដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុវត្តដូចគ្នានឹងនីតិវិធីនៃការនាំចូលទំនិញបញ្ញើទាំងនោះ។

ចំពោះទំនិញបញ្ញើដែលឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាមិនតម្រូវឱ្យមានវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចូលឡើយ ក្នុងករណី៖

១-ទំនិញបញ្ញើត្រូវបានវេចខ្ចប់ក្នុងស្ថានភាពប្រកបដោយសុវត្ថិភាព និងគ្មានហានិភ័យនៃការរាលដាលឆ្លងសមាសភាពចង្រៃ ដែលអាចកើតមាននៅក្នុងទំនិញបញ្ញើនោះ។

២-ទំនិញបញ្ញើរួមជាមួយឯកសារដែលត្រូវភ្ជាប់ ឆ្លើយតបជាមួយលក្ខខណ្ឌភូតគាមអនាម័យរបស់ប្រទេសគោលដៅ។

៣-វិញ្ញាបនបត្រភូតគាមអនាម័យនៃប្រទេសប្រភពដើម មានសង្គតិភាពជាមួយនឹងទំនិញបញ្ញើ។

**មាត្រា៥៤.-**

រាល់ទំនិញបញ្ញើជារុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ត្រូវវេចខ្ចប់ឱ្យបានគត់មត់ល្អធានាមិនរបើករហែក ហើយត្រូវផ្ទុកក្នុងមធ្យោបាយផ្ទុកដែលធានាមិនធ្លុះធ្លាយនៅក្នុងពេលដឹកជញ្ជូន។

រាល់មធ្យោបាយដឹកជញ្ជូនទំនិញបញ្ញើត្រូវធានាមិនឱ្យកើតមានហានិភ័យរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់នៅតាមផ្លូវដឹកជញ្ជូនឆ្លងកាត់។

## មាត្រា៥៥.-

ម្ចាស់ទំនិញបញ្ញើដែលដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងដល់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យប្រចាំការនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យនៃមាត់ច្រកសាមី នៅមុនពេលដែលទំនិញទាំងនោះត្រូវមកដល់ច្រកទ្វារព្រំដែន។

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវធ្វើការត្រួតពិនិត្យភូតគាមអនាម័យលើមធ្យោបាយដឹកជញ្ជូន ផ្ទៃខាងក្រៅនៃមធ្យោបាយផ្ទុកទំនិញ ត្រួតពិនិត្យវិញ្ញាបនបត្រភូតគាមអនាម័យរបស់ប្រទេសនាំចេញ និងត្រូវជំរុញការងារត្រួតពិនិត្យឱ្យបានឆាប់រហ័ស ដើម្បីសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់បន្ត។

## មាត្រា៥៦.-

ក្នុងករណីត្រួតពិនិត្យឃើញទំនិញបញ្ញើមិនទាន់ឆ្លើយតបតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យដែលបានកំណត់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច ត្រូវចាត់វិធានការភូតគាមអនាម័យជាចាំបាច់ នៅមុនពេលអនុញ្ញាតឱ្យបន្តការដឹកជញ្ជូនឆ្លងកាត់។

ក្នុងករណីមានគ្រោះថ្នាក់ដោយចៃដន្យនៅក្នុងពេលដឹកជញ្ជូនទំនិញបញ្ញើ ដែលបណ្តាលឱ្យមានការបែកបាក់ ឬរបើកសម្ភារវេចខ្ចប់ ម្ចាស់ទំនិញត្រូវរាយការណ៍ជាបន្ទាន់ដល់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច ឬអាជ្ញាធរមូលដ្ឋានដែលនៅជិតបំផុត។
មន្ត្រីភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យត្រូវចាត់ការអនុវត្តវិធានភូតគាមអនាម័យឡើងវិញជាបន្ទាន់លើទំនិញបញ្ញើ និងត្រូវផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់បន្តការនាំចេញ ឬការដឹកជញ្ជូនឆ្លងកាត់។

**មាត្រា៥៧.-**

នីតិវិធីសម្រាប់ការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចូល នាំចេញ នាំចេញបន្ត និងទំនិញឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៥
## ការគ្រប់គ្រងការរាលដាលឆ្លងសមាសភាពចង្រៃ
### ផ្នែកទី១
### តំបន់រាលដាលឆ្លងសមាសភាពចង្រៃ

**មាត្រា៥៨.-**

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិមានភារកិច្ចតាមដាន អង្កេត និងឃ្លាំមើលនូវស្ថានភាពសមាសភាពចង្រៃជាប្រចាំឬតាមដំណាក់កាល ចំពោះចរាចរណ៍រុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីចាត់វិធានការទប់ស្កាត់ការបង្ក ការរាលដាលឆ្លងសមាសភាពចង្រៃពីតំបន់មួយទៅតំបន់មួយ ឬត្រូវចាត់វិធានការលុបបំបាត់សមាសភាពចង្រៃ តាមការចាំបាច់។

នៅពេលស្រាវជ្រាវរកឃើញប្រភពបង្កសមាសភាពចង្រៃណាមួយ ឬការរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់នៅក្នុងតំបន់ណាមួយ ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវធ្វើ សេចក្តីរាយការណ៍អំពីករណីរកឃើញនេះ ជាបន្ទាន់ជូនអគ្គនាយកដ្ឋានកសិកម្ម ដើម្បីស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញប្រកាសកំណត់តំបន់ដែលបានអង្កេតឃើញ ជាតំបន់រាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យបណ្តោះអាសន្ន។

នៅក្នុងរយៈពេល៣(បី)សប្តាហ៍ បន្ទាប់ពីបានប្រកាសតំបន់រាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យបណ្តោះអាសន្ន អគ្គនាយកដ្ឋានកសិកម្មត្រូវស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចេញប្រកាសតំបន់ឬបរិវេណដែលមានការរាលដាលឆ្លង ឬសង្ស័យមានឆ្លងសមាសភាពចង្រៃនោះ ជាតំបន់ហាមឃាត់ ដើម្បីជំរុញការអនុវត្តវិធានការ ភូតគាមអនាម័យជាបន្ទាន់។

**មាត្រា៥៩.-**

នៅទីកន្លែងដែលចេញប្រកាសកំណត់ជាតំបន់ហាមឃាត់ អគ្គនាយកដ្ឋានកសិកម្ម ត្រូវចាត់វិធានការ ដូចខាងក្រោម៖

១-ផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរនូវខ្លឹមសារប្រកាសកំណត់ជាតំបន់ហាមឃាត់ដោយបញ្ជាក់នូវ៖

-ទំហំតំបន់ហាមឃាត់ច្បាស់លាស់ និងការតម្រូវក្នុងការចាត់វិធានការភូតគាមអនាម័យចំពោះម្ចាស់ឬអ្នកកាន់កាប់ដែលពាក់ព័ន្ធ

-កំណត់រយៈពេលសមស្របសម្រាប់ការហាមឃាត់

-លក្ខខណ្ឌសម្រាប់ការចេញប្រកាសជាថ្មី នៅពេលសមាសភាពចង្រៃត្រូវបានលុបបំបាត់ទាំងស្រុង។

២-បិទផ្សាយបដារូបភាព ស្លាកសញ្ញាសម្គាល់តំបន់ហាមឃាត់ សេចក្ដីជូនដំណឹង ឬទម្រង់ប្រហាក់ប្រហែល នៅជុំវិញតំបន់ដែលត្រូវហាមឃាត់។

៣-ត្រួតពិនិត្យឡើងវិញជាប្រចាំនូវស្ថានភាពសមាសភាពចង្រៃក្នុងតំបន់ហាមឃាត់ និងត្រូវជំរុញការអនុវត្តវិធានការភូតគាមអនាម័យដោយមិនបណ្ដោយឱ្យការរាលដាលឆ្លងសមាសភាពចង្រៃ អាចអូសបន្លាយពេលវេលាយូរឡើយ។

**មាត្រា៦០.-**

នៅពេលដែលការរាលដាលឆ្លងសមាសភាពចង្រៃត្រូវបានគ្រប់គ្រង និងលុបបំបាត់ អគ្គនាយកដ្ឋានកសិកម្មត្រូវស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចេញប្រកាសរំសាយចោល តំបន់រាលដាលឆ្លងសមាសភាពចង្រៃ ឬតំបន់ហាមឃាត់វិញ និងត្រូវផ្សព្វផ្សាយទៅដល់ម្ចាស់កសិដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលរងផលប៉ះពាល់នៅក្នុងតំបន់ទាំងនោះ ឬត្រូវផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា៦១.-**

ត្រូវបានប្រកាសជាតំបន់គ្មានសមាសភាពចង្រៃ ក្នុងករណីអគ្គនាយកដ្ឋានកសិកម្ម៖

១-ទទួលស្គាល់តាមរយៈការអង្កេតឃ្លាំមើលច្បាស់លាស់ ថាគ្មានវត្តមានសមាសភាពចង្រៃជាក់លាក់ណាមួយនៅក្នុងតំបន់ឡើយ។

២-មានវិធានការកម្ចាត់សមាសភាពចង្រៃ ដើម្បីថែរក្សាជាតំបន់គ្មានសមាសភាពចង្រៃ។

៣-មានប្រព័ន្ធឃ្លាំមើលដើម្បីផ្ទៀងផ្ទាត់ថាលក្ខខណ្ឌសម្រាប់តំបន់គ្មានសមាសភាពចង្រៃត្រូវបានថែរក្សាដដែល។

**មាត្រា៦២.-**

ត្រូវបានប្រកាសជាតំបន់មានសមាសភាពចង្រៃកម្រិតទាប ក្នុងករណីអគ្គនាយកដ្ឋានកសិកម្ម៖

១-ទទួលស្គាល់ថាសមាសភាពចង្រៃជាប់បញ្ញត្តិ ដែលបានកើតឡើងនៅក្នុងតំបន់មានកម្រិតទាប។

២-មានវិធានការកម្ចាត់សមាសភាពចង្រៃ ដើម្បីរក្សាកម្រិតទាបនៃសមាសភាពង្រៃ។

៣-មានប្រព័ន្ធឃ្លាំមើល ដើម្បីផ្ទៀងផ្ទាត់ថាវត្តមានសមាសភាពចង្រៃត្រូវបានទប់ស្កាត់ឱ្យនៅសល់ក្នុងកម្រិតទាប។

## ផ្នែកទី២
## វិធានការភូតគាមអនាម័យ

**មាត្រា៦៣.-**

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិ មានសមត្ថកិច្ចចាត់វិធានការភូតគាមអនាម័យ ចំពោះតំបន់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការរាលដាលឆ្លង ឬសង្ស័យថាមានការរាលដាលឆ្លងសមាសភាពចង្រៃជាប់បញ្ញត្តិ តំបន់ដែលគ្មានសមាសភាពចង្រៃ តំបន់មានសមាសភាពចង្រៃកម្រិតទាប ដូចខាងក្រោម៖

១-ធ្វើប្រព្រឹត្តិកម្ម បោះចោល ឬកម្ទេចចោលនូវទំនិញ រុក្ខជាតិ ផលិតផលរុក្ខជាតិ ឬទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត រួមទាំងការធ្វើប្រព្រឹត្តិកម្មលើមធ្យោបាយដឹកជញ្ជូន មធ្យោបាយផ្ទុកសម្ភារវេចខ្ចប់ និងមធ្យោបាយពាក់ព័ន្ធផ្សេងទៀត ទោះជាមាន ឬគ្មានការចម្លងសមាសភាពចង្រៃក្តី ក្នុងគោលដៅថែរក្សាតំបន់គ្មានសមាសភាពចង្រៃ ឬទប់ស្កាត់ឱ្យសមាសភាពចង្រៃស្ថិតក្នុងកម្រិតទាបតាមការចាំបាច់។

២-ធ្វើប្រព្រឹត្តកម្មកម្ចាត់សមាសភាពចង្រៃតាមការចាំបាច់។

៣-ហាមឃាត់ឬអនុញ្ញាតដោយភ្ជាប់លក្ខខណ្ឌ ចំពោះការធ្វើចរាចរណ៍នៅក្នុងតំបន់ ឬទៅមកពីតំបន់ដទៃទៀត នូវរុក្ខជាតិផលិតផលរុក្ខជាតិ ឬទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត។

៤-ហាមឃាត់ធ្វើការដាំដុះ ឬការដាំដុះឡើងវិញនូវរុក្ខជាតិ ឬដំណាំ នៅក្នុងទីកន្លែងដែលកំពុងរងការរាតត្បាតដោយសមាសភាពចង្រៃ។

៥-អនុវត្តវិធានការភូតគាមអនាម័យដទៃទៀតតាមការចាំបាច់។

**មាត្រា៦៤.-**

ការនាំយកសំណាកសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ពីតំបន់រាលដាលឆ្លងសមាសភាពចង្រៃ ទៅតំបន់ដែលគ្មានការរាតត្បាត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការវិភាគ ត្រូវមានការអនុញ្ញាតពីភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច។

ការដឹកជញ្ជូនទំនិញចេញ ចូល ឬឆ្លងកាត់តំបន់រាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្អាកជាបណ្តោះអាសន្នរហូតដល់មានប្រកាសលុបចោលតំបន់ហាមឃាត់ ជាថ្មីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៦៥.-**

ដោយយោងតាមរបាយការណ៍របស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច ដែលបានអង្កេត វាយតម្លៃ ឬអះអាងថាស្ថានភាពរាលដាលឆ្លងសមាសភាពចង្រៃ នៅក្នុងតំបន់ណាមួយ ជាករណីផ្ទុះសមាសភាពចង្រៃកម្រិតធ្ងន់ធ្ងរ អគ្គនាយកដ្ឋានកសិកម្មត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំចេញប្រកាសស្តីពីករណីគ្រោះបន្ទាន់ភូតគាមអនាម័យ ដែលត្រូវជំរុញការចាត់វិធានការភូតគាមអនាម័យគ្រាអាសន្ន។

វិធានការភូតគាមអនាម័យគ្រាអាសន្ន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៦៦.-**

ផលិតផលឈើកែច្នៃឬមិនទាន់កែច្នៃ មធ្យោបាយផ្ទុក សំបកវេចខ្ចប់ ឬប៉ាឡែតទ្រទំនិញ ដែលផលិតអំពីឈើ ចាំបាច់ត្រូវឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មភូតគាមអនាម័យ ដោយអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីវិធានការភូតគាមអនាម័យចំពោះផលិតផលឈើ និងកំណត់សញ្ញាសម្គាល់អន្តរជាតិ ជាធរមាន។

**មាត្រា៦៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ជាម្ចាស់នៃទំនិញបញ្ញើ ឬម្ចាស់គ្រឹះស្ថាន ត្រូវបង្កលក្ខណៈឱ្យភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច អាចចូលក្នុងគ្រឹះស្ថានផលិតកម្ម កសិដ្ឋាន ឃ្លាំងសន្និធិ មធ្យោបាយដឹកជញ្ជូននិងមធ្យោបាយផ្ទុកគ្រប់ប្រភេទ ដើម្បីបំពេញសមត្ថកិច្ចត្រួតពិនិត្យភូតគាមអនាម័យ ឬចាត់វិធានការភូតគាមអនាម័យ ដោយអនុលោមតាមបទប្បញ្ញត្តិនិង នីតិវិធីនៃច្បាប់នេះ។

ម្ចាស់ អ្នកកាន់កាប់ ឬអ្នកទទួលខុសត្រូវចំពោះទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យគ្រប់ប្រភេទ មានកាតព្វកិច្ចអនុវត្តវិធានការបន្ទាន់ នៅក្នុងការទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃណាមួយ នៅពេលដែលបុគ្គលនោះបានឃើញ ឬបានដឹងថាទំនិញឬទំនិញបញ្ញើជាកម្មសិទ្ធិរបស់ខ្លួន ត្រូវបានបំផ្លាញដោយសមាសភាពចង្រៃភូតគាមអនាម័យ។

ម្ចាស់កសិដ្ឋាន ម្ចាស់ដី ឬម្ចាស់គ្រឹះស្ថានទាំងឡាយដែលបានឃើញ ឬសង្ស័យថាអចលនទ្រព្យជាកម្មសិទ្ធិរបស់ខ្លួន ឬស្ថិតក្រោមសិទ្ធិទទួលខុសត្រូវរបស់ខ្លួន មានវត្តមានឬកំពុងយាយីរដោយសមាសភាពចង្រៃភូតគាមអនាម័យណាមួយ ត្រូវជូនដំណឹងជាបន្ទាន់ជូនភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិ ដែលនៅជិតបំផុត ដើម្បីជួយអន្តរាគមន៍ចាត់វិធានការភូតគាមអនាម័យ ជាបន្ទាន់។

**មាត្រា៦៨.-**

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិ មានសិទ្ធិជូនដំណឹងទៅម្ចាស់កសិដ្ឋានណាមួយ ដើម្បីតម្រូវឱ្យចាត់វិធានការភូតគាមអនាម័យនៅក្នុងកសិដ្ឋានរបស់ខ្លួន ។

ក្នុងករណីម្ចាស់កសិដ្ឋានបដិសេធមិនព្រមអនុវត្តតាមសេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចមានសិទ្ធិចូលក្នុងបរិវេណ កសិដ្ឋាននោះ ដើម្បីសាកសួរ និងបញ្ជាក់ជូនម្ចាស់កសិដ្ឋានអំពីភាពចាំបាច់នៃការអនុវត្តវិធានការភូតគាម អនាម័យ ដែលត្រូវបំផ្លាញចោលនូវរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ក្នុងគោលបំណងទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃ។

## មាត្រា៦៩.-

ម្ចាស់កសិដ្ឋានត្រូវទទួលបន្ទុកលើការខាតបង់ចំពោះធនធានរុក្ខជាតិ និងផលិតផលរុក្ខជាតិឬទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀតរបស់ខ្លួន ដែលត្រូវបំផ្លាញចោលនៅក្នុងការអនុវត្តវិធានការភូតគាមអនាម័យ។

រាជរដ្ឋាភិបាលទទួលបន្ទុកទ្រទ្រង់លើដំណើរការអនុវត្តវិធានការភូតគាមអនាម័យ ដើម្បីទប់ស្កាត់ការរាលដាលឆ្លង និងការលុបបំបាត់សមាសភាពចង្រៃភូតគាមអនាម័យ ដែលអនុវត្តដោយអង្គភាពជាតិការពាររុក្ខជាតិ ប៉ុន្តែមិនទទួលបន្ទុកជួសជុលការខូចខាតណាមួយរបស់ម្ចាស់កសិដ្ឋាន ដែលកើតឡើងដោយសារការបំផ្លាញចោលនូវធនធានរុក្ខជាតិ ផលិតផលរុក្ខជាតិ ឬទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត នៅក្នុងការអនុវត្តវិធានការភូតគាមអនាម័យក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះឡើយ។

## មាត្រា៧០.-

នៅពេលដឹកជញ្ជូនទំនិញបញ្ញើជាប់បញ្ញតិ ក្នុងករណីជួបគ្រោះថ្នាក់ចរាចរណ៍ ឬកញ្ចប់ទំនិញត្រូវបានរហែក ធ្លុះធ្លាយ ដែលបង្កភាពរាយប៉ាយមកខាងក្រៅនូវទំនិញជាប់បញ្ញត្តិទាំងនោះ ម្ចាស់ ឬអ្នកទទួលខុសត្រូវលើមធ្យោបាយដឹកជញ្ជូន ឬលើទំនិញបញ្ញើ ត្រូវជូនព័ត៌មានជាបន្ទាន់ជូនភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិដែលនៅជិតបំផុត ឬអាជ្ញាធរមូលដ្ឋាននៅនឹងកន្លែង ដើម្បីជួយអន្តរាគមន៍ និងចាត់វិធានការភូតគាមអនាម័យជាបន្ទាន់។

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចនៅនឹងកន្លែង ត្រូវចាត់វិធានការបន្ទាន់ធ្វើប្រព្រឹត្តិកម្មភូតគាមអនាម័យក្នុងករណីកើតមានហានិភ័យសមាសភា

ពចង្រៃ និងត្រូវ ចាត់វិធានការបន្តបន្ទាប់ អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃហានិភ័យសមាសភាពចង្រៃ។

**មាត្រា៧១.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចជូនព័ត៌មានឬដំណឹងជាបន្ទាន់ ជូនភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិដែលនៅជិតបំផុត ឬអាជ្ញាធរមូលដ្ឋាននៅនឹងកន្លែង ក្នុងករណីបានជួបហេតុការណ៍ ដូចខាងក្រោម៖

១- មធ្យោបាយដឹកជញ្ជូនផ្លូវគោកគ្រប់ប្រភេទ ដែលផ្ទុកនូវទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលបានធ្លុះធ្លាយ និងធ្លាក់រាយប៉ាយនៅលើទីតាំងណាមួយក្នុង ព្រះរាជាណាចក្រកម្ពុជា។

២-នាវា កាណូត ទូក ឬមធ្យោបាយដឹកជញ្ជូនផ្លូវទឹក ណាមួយ ដែលផ្ទុកនូវទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលបានធ្លុះធ្លាយនិងធ្លាក់ចូលក្នុងដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា។

៣-យន្តហោះឬមធ្យោបាយដឹកជញ្ជូនផ្លូវអាកាសគ្រប់ប្រភេទ ដែលបានទម្លាក់នូវទំនិញបញ្ញើជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ចុះមកក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៧២.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវកំណត់ទីកន្លែងសមស្របសម្រាប់ការបង្កើតស្ថានីយភូតគាមចត្តាឡីសក័ ដើម្បីរក្សាទុកសំណាកទំនិញ រុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ព្រមទាំងសម្ភារនាំចូលផ្សេងៗទៀត សម្រាប់ការធ្វើវិភាគហានិភ័យសមាសភាពចង្រៃ ការអង្កេតស្រាវជ្រាវ ការធ្វើតេស្ត ការធ្វើប្រព្រឹត្តិកម្ម ឬការបំផ្លាញចោល។

**មាត្រា៧៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នជាតិ អង្គការអន្តរជាតិឬតំបន់ដែលពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន

ដើម្បីធ្វើបច្ចុប្បន្នភាពនូវវិធានការភូតគាមអនាម័យ ដែលអាចប្រែប្រួលតាមហានិភ័យសមាសភាពចង្រៃនិងសក្តានុពលផ្ទុះសមាសភាពចង្រៃ ស្របតាមព្រឹត្តិការណ៍ភូតគាមអនាម័យ។

**មាត្រា៧៤.-**

ក្រោមគោលបំណងនៃការគ្រប់គ្រងការរាលដាលឆ្លងសមាសភាពចង្រៃគ្រប់រូបភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាស ស្តីពីៈ

១-វិធានការទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ និងការលុបបំបាត់សមាសភាពចង្រៃមិនមែនភូតគាមអនាម័យជាប់បញ្ញត្តិ។

២-វិធានការទប់ស្កាត់ការរាលដាលឆ្លង ការនាំចូល និងការលុបបំបាត់សមាសភាពចង្រៃប្រភេទថ្មីឈ្លានពាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-ការបង្កើតនិងវិធានការថែទាំតំបន់គ្មានសមាសភាពចង្រៃ និងតំបន់មានសមាសភាពចង្រៃកម្រិតទាប។

## ជំពូកទី៦
## បញ្ជីសមាសភាពចង្រៃ និងការវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ

**មាត្រា៧៥.-**

នាយកដ្ឋានការពាររុក្ខជាតិ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិត្រូវសិក្សា រៀបចំ និងចងក្រងបញ្ជីសមាសភាពចង្រៃ តាមក្រុមប្រភេទដំណាំឬរុក្ខជាតិតាមតំបន់ដែលរាតត្បាត និងតាមប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដោយធ្វើការចាត់ថ្នាក់ជាក្រុមសមាសភាពចង្រៃភូតគាមអនាម័យ សមាសភាពចង្រៃមិនមែនភូតគាមអនាម័យជាប់បញ្ញត្តិ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដោយអនុលោមតាមស្តង់ដារនៃអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ។

បញ្ជីសមាសភាពចង្រៃភូតគាមអនាម័យ សមាសភាពចង្រៃមិនមែនភូតគាមអនាម័យជាប់បញ្ញត្តិ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ត្រូវបានប្រើប្រាស់ក្នុងការធ្វើវិភាគហានិភ័យ ទំនិញបម្រុងនាំចូលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ។

បញ្ជីសមាសភាពចង្រៃក្នុងស្រុក ត្រូវបានរាប់បញ្ចូលបណ្តាសមាសភាពចង្រៃទាំងអស់ដែលយាយីរលើគ្រប់ក្រុមប្រភេទដំណាំឬរុក្ខជាតិ ដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រ កម្ពុជាត្រូវបានប្រើប្រាស់ជាបញ្ជីមូលដ្ឋាន សម្រាប់ធ្វើវិភាគហានិភ័យសមាសភាពចង្រៃទំនិញបម្រុងនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

## មាត្រា៧៦.-

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិត្រូវចងក្រងបញ្ជី ឬធ្វើបច្ចុប្បន្នភាពនៃបញ្ជីសមាសភាពចង្រៃភូតគាមអនាម័យ សមាសភាពចង្រៃមិនមែនភូតគាមអនាម័យជាប់បញ្ញត្តិ សមាសភាពចង្រៃបង្កគ្រោះថ្នាក់ និងសមាសភាពចង្រៃក្នុងស្រុកសម្រាប់ការប្រើប្រាស់ជាផ្លូវការនៅក្នុងការគ្រប់គ្រង ភូតគាមអនាម័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិត្រូវសិក្សាស្រាវជ្រាវតាមរយៈការធ្វើអត្តសញ្ញាណកម្ម និងការធ្វើវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ ដោយផ្តោតទៅលើការធ្វើបច្ចុប្បន្នភាពប្រភេទសមាសភាពចង្រៃដែលមានវត្តមានថ្មីៗនៅក្នុងការគ្រប់គ្រងភូតគាមអនាម័យ ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះសមាសភាពចង្រៃប្រភេទថ្មីឈ្លានពាន ដែលត្រូវចាត់ថ្នាក់ក្នុងបញ្ជីសមាសភាពចង្រៃគ្រោះថ្នាក់។

បញ្ជីសមាសភាពចង្រៃរួមជាមួយផ្នែកបច្ចុប្បន្នភាព ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយចំពោះភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យនៃអង្គភាពជាតិការពាររុក្ខជាតិ មន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រាជធានី ខេត្ត ម្ចាស់កសិដ្ឋាន សហគមន៍កសិកម្ម និងអ្នកពាក់ព័ន្ធផ្សេងទៀត ជាផ្នែកមួយសម្រាប់ការអប់រំការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ។

**មាត្រា៧៧.-**

ក្នុងក្របខណ្ឌនៃការចងក្រងបញ្ជីសមាសភាពចង្រៃនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងគ្រឹះស្ថានស្រាវជ្រាវពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យ និងសំណាកសមាសភាពចង្រៃលើគ្រប់ក្រុមប្រភេទ ដំណាំឬរុក្ខជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើតបណ្ណាល័យសមាសភាពចង្រៃ ដើម្បីរក្សាទុកសំណាកសមាសភាពចង្រៃគ្រប់ប្រភេទ សម្រាប់ការសិក្សាស្រាវជ្រាវ និងប្រើប្រាស់ជាសំណាកផ្ទៀងផ្ទាត់នៅក្នុងការវិភាគហានិភ័យសមាសភាពចង្រៃ។

**មាត្រា៧៨.-**

បញ្ជីសមាសភាពចង្រៃ សម្រាប់ការគ្រប់គ្រងភូតគាមអនាម័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៧៩.-**

ក្នុងក្របខណ្ឌនៃការគ្រប់គ្រងភូតគាមអនាម័យប្រកបដោយលក្ខណៈវិទ្យាសាស្ត្រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើតមណ្ឌលនិងអនុមណ្ឌលវិនិច្ឆ័យភូតគាមសមាសភាពចង្រៃស្ថិតក្រោមអង្គភាពជាតិការពាររុក្ខជាតិដូចខាងក្រោម៖

១-មណ្ឌលវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ ដែលមានមុខងារជាមន្ទីរពិសោធន៍ ក្នុងការកំណត់អត្តសញ្ញាណកម្ម និងធ្វើវិនិច្ឆ័យភូតគាមសមាសភាពចង្រៃនៅថ្នាក់ជាតិ ស្របតាម ស្តង់ដារអន្តរជាតិនៃវិធានការភូតគាមអនាម័យ។

២-អនុមណ្ឌលវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ ដែលត្រូវបង្កើតឡើងនៅគ្រប់ការិយាល័យសាខាភូតគាមអនាម័យប្រចាំតំបន់ ដែលមានសក្តានុពលរាលដាលឆ្លងសមាសភាពចង្រៃ។

**មាត្រា៨០.-**

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យដែលជាអង្គភាពជាតិការពាររុក្ខជាតិ

ដែលជាអង្គភាពមានសមត្ថកិច្ចតែមួយគត់ ដែលទទួលខុសត្រូវ និងមានសិទ្ធិក្នុងការផ្ញើសំណាកសមាសភាពចង្រៃចេញទៅក្រៅប្រទេសដើម្បីកំណត់អត្តសញ្ញាណកម្ម ឬកំណត់អត្តសញ្ញាណកម្មឡើងវិញ និងធ្វើវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ។

ព័ត៌មានអំពីការផ្ញើសំណាកសមាសភាពចង្រៃចេញទៅក្រៅប្រទេស ត្រូវបានចាត់ទុកជាការសម្ងាត់ ដែលសំណាកបញ្ញើត្រូវកំណត់លេខកូដសម្គាល់ដោយអង្គភាពជាតិការពាររុក្ខជាតិស្របតាមស្តង់ដារអន្តរជាតិនៃវិធានការភូតគាមអនាម័យ។

## ជំពូកទី៧
## យន្តការគាំទ្រការការពាររុក្ខជាតិ និងភូតគាមអនាម័យ

### ផ្នែកទី១
### ការស្រាវជ្រាវ និងការពង្រឹងសមត្ថភាព ភូតគាមអនាម័យ

**មាត្រា៨១.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវគាំទ្រនិងជំរុញការអនុវត្តកម្មវិធីស្រាវជ្រាវ និងការពង្រឹងសមត្ថភាពភូតគាមអនាម័យ ដូចខាងក្រោម៖

១-ការស្រាវជ្រាវប្រព័ន្ធមូលដ្ឋានទិន្នន័យភូតគាមអនាម័យ។

២-ការស្រាវជ្រាវអំពីសមាសភាពចង្រៃ ការវិភាគហានិភ័យនិងការចាត់វិធានការភូតគាមអនាម័យ។

៣-ការស្រាវជ្រាវអំពីហានិភ័យគ្រោះថ្នាក់នៅក្នុងការអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ។

៤-ការពង្រឹងសមត្ថភាពភូតគាមអនាម័យនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសសម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ ។

៥-ការពង្រឹងសមត្ថភាពធនធានមនុស្ស និងការលើកកម្ពស់គុណវឌ្ឍិរបស់មន្ត្រីជំនាញសម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ។

៦-ការផ្សព្វផ្សាយអប់រំ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ។

៧-ការងារស្រាវជ្រាវផ្សេងទៀត នៅក្នុងក្របខណ្ឌនៃការពង្រឹងសមត្ថភាពភូតគាមអនាម័យ។

**មាត្រា៨២.-**

មន្ទីរពិសោធន៍ជាតិកសិកម្ម មណ្ឌល និងអនុមណ្ឌលវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ ឬអង្គភាពជំនាញចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបំពេញភារកិច្ចផ្តល់សេវាកម្មបច្ចេកទេស ក្នុងក្របខណ្ឌនៃការអនុវត្តវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ មានសិទ្ធិអភិវឌ្ឍជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៨៣.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានវិជ្ជាជីវៈជំនាញដែលបានទទួលស្គាល់ស្របតាមច្បាប់ជាធរមានមានសិទ្ធិស្នើសុំផ្តល់សេវាកម្មភូតគាមអនាម័យ ឬផ្តល់សេវាកម្មអន្តរាគមន៍ពាក់ព័ន្ធវិធានការភូតគាមអនាម័យ រួមមាន៖

-សេវាកម្មប្រព្រឹត្តកម្មភូតគាមអនាម័យគ្រប់ប្រភេទ

-ការបង្កើតមន្ទីរពិសោធន៍និងស្ថានីយពិសោធន៍

-អ្នកស្រាវជ្រាវ អ្នកធ្វើវិភាគ អ្នកធ្វើពិសោធន៍ បុគ្គលិកបច្ចេកទេស

-សេវាកម្មផ្សេងទៀតក្នុងក្របខណ្ឌនៃវិធានការភូតគាមអនាម័យ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលធ្វើសេវាកម្មភូតគាមអនាម័យពាក់ព័ន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវបំពេញលក្ខខណ្ឌតម្រូវស្របតាមនីតិវិធីនិងបទប្បញ្ញត្តិនៃច្បាប់នេះ។

មន្ទីរពិសោធន៍និងស្ថានីយពិសោធន៍ត្រូវមានការទទួលស្គាល់ពីគ្រឹះស្ថានជាតិឬអន្តរជាតិសម្រាប់ផ្តល់ការទទួលស្គាល់ ស្របតាមច្បាប់ជាធរមាន។

អ្នកស្រាវជ្រាវ អ្នកធ្វើវិភាគ អ្នកធ្វើពិសោធន៍ បុគ្គលិកបច្ចេកទេស ត្រូវមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងការផ្តល់សេវាកម្មភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# ផ្នែកទី២
# មូលនិធិបន្ទាន់សម្រាប់ការការពាររុក្ខជាតិ
# និងភូតគាមអនាម័យ

## មាត្រា៨៤.-

ត្រូវបង្កើតមូលនិធិបន្ទាន់សម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ក្នុងក្របខណ្ឌនៃការគាំទ្រវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ។

ការគ្រប់គ្រង និងចាត់ចែងមូលនិធិបន្ទាន់សម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា៨៥.-

មូលនិធិបន្ទាន់សម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ មានប្រភពចំណូលដូចខាងក្រោម៖

១-ថវិកាជាតិប្រចាំឆ្នាំ។

២-គម្រោងជំនួយពីប្រភពនានា។

៣-ប្រាក់ចំណូលសេវាសាធារណៈក្នុងការគ្រប់គ្រងការការពាររុក្ខជាតិនិងភូតគាមអនាម័យ។

៤-ប្រាក់ពិន័យដែលបានមកពីការជំរុញអនុវត្តន៍ច្បាប់នេះ។

៥-ប្រភពហិរញ្ញវត្ថុផ្សេងទៀត។

រាល់ថវិកាចំណូលរបស់មូលនិធិដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបញ្ចូលក្នុងគណនីមូលនិធិបន្ទាន់សម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ។

## មាត្រា៨៦.-

មូលនិធិបន្ទាន់សម្រាប់ការការពាររុក្ខជាតិនិងភូតគាមអនាម័យ អាចប្រើប្រាស់ចំពោះតែសកម្មភាពដូចខាងក្រោម៖

១-វិធានការបន្ទាន់ឥតគ្រោងទុកសម្រាប់យុទ្ធនាការជាក់លាក់ ក្នុងការទប់ស្កាត់ការរាលដាលឆ្លងការផ្ទុះឡើងសមាសភាពចង្រៃការកម្ចាត់ ឬការលុបបំបាត់ការរាតត្បាតពីសំណាក់សមាសភាពចង្រៃ។

២-ការស្រាវជ្រាវអំពីសមាសភាពចង្រៃជាក់លាក់ និងការវិភាគហានិភ័យ។

៣-ការបង្កើតតំបន់គ្មានសមាសភាពចង្រៃ និងការថែទាំ។

៤-ការគ្រប់គ្រងស្ថានភាពជាក់លាក់នៃតំបន់ផ្ទុះឡើងសមាសភាពចង្រៃ ឬតំបន់ហាមឃាត់។

៥-ចលនាផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈសម្រាប់ករណីជាក់លាក់នៃការរាលដាលឆ្លងឬការផ្ទុះឡើងសមាសភាពចង្រៃ។

៦-ការបំពេញភារកិច្ចអន្តរជាតិរបស់អង្គភាពជាតិការពាររុក្ខជាតិ ក្នុងក្របខណ្ឌនៃការអនុវត្តអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ។

៧-សកម្មភាពគាំទ្រចាំបាច់ផ្សេងទៀត ដែលសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៨
## ការគ្រប់គ្រងព័ត៌មានភូតគាមអនាម័យ និងការផ្សព្វផ្សាយ

**មាត្រា៨៧.-**

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិមានតួនាទីជាសមត្ថកិច្ចជាតិតែមួយគត់ ក្នុងការគ្រប់គ្រងព័ត៌មានភូតគាមអនាម័យ ដែលពាក់ព័ន្ធនឹងវត្តមានសមាសភាពចង្រៃ និងការផ្ទុះឡើងសមាសភាពចង្រៃ ដែលត្រូវចាត់ទុកថាជាព័ត៌មានសម្ងាត់ និងពាក់ព័ន្ធចំពោះផលប្រយោជន៍ជាតិ។

រូបវន្តបុគ្គលឬនីតិបុគ្គល រួមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដែលមានបំណងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធវត្តមានសមាសភាពចង្រៃ ឬការផ្ទុះឡើងសមាសភាពចង្រៃ និងព័ត៌មានភូតគាមអនាម័យផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំ និងត្រូវយោងតាមព័ត៌មានដែលបញ្ចេញជាផ្លូវការដោយអង្គភាពជាតិការពាររុក្ខជាតិ នៅមុនពេលធ្វើការផ្សព្វផ្សាយជាសាធារណៈ។

រូបវន្តបុគ្គលឬនីតិបុគ្គល រួមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា ដែលផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានភូតគាមអនាម័យ ផ្ទុយពីព័ត៌មានផ្លូវការដែលបញ្ចេញដោយអង្គភាពជាតិការពាររុក្ខជាតិដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវចាត់ទុកជាការផ្សព្វផ្សាយព័ត៌មានមិនពិត មិនផ្លូវការ និងបង្កផលប៉ះពាល់ដល់ប្រយោជន៍ជាតិ ដែលត្រូវប្រឈមចំពោះទណ្ឌកម្មក្រោមច្បាប់នេះ ដោយមិនទាន់គិតពីព្យសនកម្មដែលបណ្ដាលមកពីការផ្សព្វផ្សាយព័ត៌មាននោះ។

**មាត្រា៨៨.-**

រាល់ការផ្សព្វផ្សាយ ការធ្វើបង្ហាញ ឬការផ្សព្វផ្សាយតាមរូបភាពផ្សេងទៀតអំពីការអនុវត្តវិធានការការពាររុក្ខជាតិឬវិធានការភូតគាមអនាម័យអំពីការប្រើប្រាស់ផលិតផលការពាររុក្ខជាតិ និងផលិតផលផ្សេងទៀតដែលមានប្រសិទ្ធភាពក្នុងការអនុវត្តវិធានការការពាររុក្ខជាតិឬវិធានការភូតគាមអនាម័យត្រូវឆ្លងកាត់ការពិនិត្យ ការសិក្សាលើទិដ្ឋភាពបច្ចេកទេស និងការទទួលយកសេចក្ដីវាយតម្លៃរបស់នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិ។

**មាត្រា៨៩.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈក្នុងក្របខណ្ឌនៃការការពាររុក្ខជាតិនិងភូតគាមអនាម័យនៅក្នុងផលិតកម្មកសិកម្ម និងក្នុងពាណិជ្ជកម្ម រុក្ខជាតិ និងផលិតផលរុក្ខជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវអនុវត្តការងារផ្សព្វផ្សាយឱ្យបានទូលំទូលាយណែនាំការងារអនុវត្ត និងការបញ្ជ្រាបបច្ចេកទេសការពាររុក្ខជាតិដល់ប្រជាកសិករ ម្ចាស់កសិដ្ឋាន និងសហគមន៍ មូលដ្ឋាន នូវរាល់វិធានការបង្ការ និងកម្ចាត់សមាសភាពចង្រៃ ដែលបំផ្លាញរុក្ខជាតិនិងដំណាំ និងបង្កការខាតបង់នៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម។

**មាត្រា៩០.-**

ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីសុខភាពរុក្ខជាតិ និងការអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងអំពីសារៈសំខាន់នៃការចូលរួមក្នុងការការពាររុក្ខជាតិ ការរក្សាសុវត្ថិភាពស្បៀង និងផលិតផលដំណាំ ការធានាសុវត្ថិភាពចំពោះសុខុមាលភាពនិងសុខភាពសាធារណៈ ព្រមទាំងរក្សាបាននូវនិរន្តភាពនៃប្រព័ន្ធក្សេត្របរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលត្រូវកំណត់យក**ថ្ងៃទី៣០ ខែមេសា** រៀងរាល់ឆ្នាំ ជា "**ទិវាជាតិសុវត្ថិភាពស្បៀង**"។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រារព្ធទិវាជាតិសុវត្ថិភាពស្បៀង ដោយរៀបចំ និងចាត់តាំងសកម្មភាព ដែលមានការចូលរួមពីមហាជននិងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន និងមានការគាំទ្ររបស់អង្គការសង្គមពាក់ព័ន្ធ ក្នុងនោះការបញ្ច្រាបយេនឌ័រត្រូវបានលើកទឹកចិត្តជាអាទិភាព។

**មាត្រា៩១.-**

នីតិវិធី ការគ្រប់គ្រងព័ត៌មានភូតគាមអនាម័យ និងការផ្សព្វផ្សាយពាក់ព័ន្ធវិធានការការពាររុក្ខជាតិនិងភូតគាមអនាម័យត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៩
## ភាតព្វកិច្ចប្រតិបត្តិករ

**មាត្រា៩២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើប្រតិបត្តិការក្នុងក្របខណ្ឌនៃប្រព័ន្ធវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យឬធ្វើសកម្មភាពពាក់ព័ន្ធរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀតក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលខុសត្រូវលើរាល់សកម្មភាពរបស់ខ្លួន និងត្រូវបង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាពអប់រំណែនាំ ត្រួតពិនិត្យ និងអនុវត្តច្បាប់របស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

**មាត្រា៩៣.-**

ប្រតិបត្តិករត្រូវចុះក្នុងសៀវភៅកំណត់ត្រាសេវាកម្មការពាររុក្ខជាតិនិងភូតគាមអនាម័យ នូវរាល់ព័ត៌មាននិងទិន្នន័យពាក់ព័ន្ធប្រតិបត្តិការរបស់ខ្លួន អំពីសេវាកម្មការពាររុក្ខជាតិឬសេវាកម្មភូតគាមអនាម័យដែលបានអនុវត្ត ប្រភេទផលិតផលការពាររុក្ខជាតិដែលប្រើប្រាស់ និងវិធានសុវត្ថិភាពដែលបានអនុវត្តនៅក្នុងប្រតិបត្តិការផ្តល់សេវាកម្មពាក់ព័ន្ធ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ សម្រាប់ការតាមដាននិងការត្រួតពិនិត្យរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច។

គំរូសៀវភៅកំណត់ត្រាសេវាកម្មការពាររុក្ខជាតិនិងភូតគាមអនាម័យ ត្រូវកំណត់ដោយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៩៤.-**

ប្រតិបត្តិករដែលកាន់កាប់លិខិតអនុញ្ញាតធ្វើសេវាកម្មក្នុងក្របខណ្ឌនៃប្រព័ន្ធវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យពាក់ព័ន្ធក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ មានកាតព្វកិច្ចដូចខាងក្រោម៖

១-ត្រូវអនុវត្តតាមបទបញ្ជា លក្ខខណ្ឌ និងរយៈពេលសុពលភាពដែលកំណត់ក្នុងលិខិតអនុញ្ញាត។

២-ទទួលខុសត្រូវចំពោះមុខច្បាប់នេះលើរាល់ប្រតិបត្តិការរបស់សាខាចំណុះនិងសកម្មភាពរបស់និយោជិតរបស់ខ្លួនចំពោះអំពើល្មើស ឬការរំលោភលើបទប្បញ្ញត្តិនៃច្បាប់នេះដែលកើតចេញពីប្រតិបត្តិការពាក់ព័ន្ធ។

៣-ទទួលខុសត្រូវចំពោះការរាលដាលឆ្លងសមាសភាពចង្រៃឬចំពោះហានិភ័យគ្រោះថ្នាក់ផ្សេងទៀតដែលកើតឡើងនៅក្នុងប្រតិបត្តិការផ្តល់សេវាកម្មការពាររុក្ខជាតិឬភូតគាមអនាម័យ។

៤-ត្រូវមានបុគ្គលិកបច្ចេកទេសដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីទទួលខុសត្រូវជាអចិន្ត្រៃយ៍លើក្របខណ្ឌបច្ចេកទេសស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

៥-ត្រូវស្នើសុំការយល់ព្រមជាមុន ចំពោះការផ្ទេរសិទ្ធិកាន់កាប់លិខិតអនុញ្ញាតពាក់ព័ន្ធ។

**មាត្រា៩៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើប្រតិបត្តិការពាក់ព័ន្ធ ការធ្វើសេវាកម្ម និងធ្វើប្រតិបត្តិការផ្សេងៗទៀត ក្នុងក្របខណ្ឌនៃប្រព័ន្ធវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ មានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈតាមករណីស្នើសុំនីមួយៗ។

កម្រៃសេវាសាធារណៈតាមប្រភេទប្រតិបត្តិការ និងតាមប្រភេទសេវាកម្មការពាររុក្ខជាតិនិងភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី១០
## ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ និង
## ការជំរុញអនុវត្តន៍ច្បាប់

**មាត្រា៩៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលខុសត្រូវក្នុងការជំរុញអនុវត្តន៍ច្បាប់នេះ តាមរយៈនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដែលជាអង្គភាពជាតិការពាររុក្ខជាតិ ដើម្បីជានាការពារទប់ស្កាត់ និងលុបបំបាត់ការរាលដាលឆ្លងសមាសភាពចង្រៃគ្រប់ប្រភេទ និងសារជាតុពុលក្នុងផលិតផលកសិកម្ម និងស្បៀងអាហារនេះ។

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច នៃអង្គភាពជាតិការពាររុក្ខជាតិត្រូវបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមគុណវុឌ្ឍិជំនាញវិជ្ជាជីវៈរបស់ខ្លួន ដើម្បីបំពេញតួនាទីនិងភារកិច្ចក្នុងការជំរុញអនុវត្តន៍ច្បាប់នេះ។

**មាត្រា៩៧.-**

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ មានសមត្ថកិច្ចតាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យជាប្រចាំនូវរាល់សកម្មភាពដែលពាក់ព័ន្ធរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត នៅក្នុងដែនសមត្ថកិច្ចសាមីក្នុងគោលបំណង បង្កាទប់ស្កាត់ការរាលដាលឆ្លង ការរាតត្បាត

និងការលុបបំបាត់ហានិភ័យសមាសភាពចង្រៃ និងជំរុញការអនុវត្តច្បាប់នេះ នៅតាមទីកន្លែងដូចខាងក្រោម៖

-ស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ

-ការិយាល័យសាខាភូតគាមអនាម័យប្រចាំតំបន់ និងស្ថានីយភូតគាមចត្តាឡីសក័

-ក្នុងបរិវេណកសិដ្ឋាន មណ្ឌលលំនៅដ្ឋាន សួនរុក្ខជាតិគ្រប់ប្រភេទដែលអនុវត្តផលិតកម្មដំណាំ ឬរុក្ខជាតិលម្អ

-គ្រឹះស្ថានពាណិជ្ជកម្ម កន្លែងធ្វើសន្និធិផលិតផលការពាររុក្ខជាតិគ្រប់ប្រភេទ និងកន្លែងរក្សាទុកទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ

-គ្រឹះស្ថានស្រាវជ្រាវ មន្ទីរពិសោធន៍ ស្ថានីយពិសោធន៍ និងគ្រឹះស្ថានធ្វើសេវាកម្មដែលពាក់ព័ន្ធវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ

-មធ្យោបាយដឹកជញ្ជូននិងមធ្យោបាយផ្ទុកទំនិញ រុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត

-ទីកន្លែងផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានហានិភ័យ ឬសង្ស័យថាមានហានិភ័យសមាសភាពចង្រៃឬសង្ស័យថាមានបទល្មើសពាក់ព័ន្ធ ដូចមានចែងក្នុងច្បាប់នេះ។

**មាត្រា៩៨.-**

នៅក្នុងប្រតិបត្តិការជំរុញការអនុវត្តន៍ច្បាប់ ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសិទ្ធិនិងភារកិច្ច ដូចខាងក្រោម៖

១-តម្រូវឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសកម្មភាពពាក់ព័ន្ធរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀតផ្តល់ព័ត៌មាន និងបង្ហាញវិញ្ញាបនបត្រ លិខិតអនុញ្ញាត និងឯកសារពាក់ព័ន្ធនៅក្នុងសកម្មភាពរបស់ខ្លួន។

២-ដកយកសំណាកផលិតផលការពាររុក្ខជាតិ វត្ថុវិភាគរុក្ខជាតិ ផលិតផលរុក្ខជាតិនិងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ដើម្បីសិក្សា វាយតម្លៃផ្នែកបច្ចេកទេស និងធ្វើវិភាគហានិភ័យសមាសភាពចង្រៃ។

៣-ដកហូតជាបណ្តោះអាសន្ននូវវិញ្ញាបនបត្រ លិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធ និងចាប់យកវត្ថុតាង ក្នុងករណីអ្នកកាន់វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតនោះ ប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

៤-ចាត់វិធានការផ្អាកជាបណ្តោះអាសន្នរាល់សកម្មភាពពាក់ព័ន្ធក្នុងក្របខណ្ឌនៃការអនុវត្តវិធានការការពាររុក្ខជាតិ និងវិធានការភូតគាមអនាម័យ។

៥-បំពេញសំណុំបែបបទនៃករណីបទល្មើស ចាត់វិធានការដោះស្រាយបទល្មើសស្របតាមច្បាប់នេះ ឬចងក្រងសំណុំរឿងនៃបទល្មើស ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

៦-បំពេញភារកិច្ចផ្សេងទៀត ក្នុងក្របខណ្ឌនៃការជំរុញអនុវត្តន៍ច្បាប់នេះ។

**មាត្រា៩៩.-**

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបានផ្តល់នីតិសម្បទាឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ដោយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ការផ្តល់នីតិសម្បទាចំពោះភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា១០០.-**

នៅពេលចេញប្រតិបត្តិការជំរុញការអនុវត្តច្បាប់ ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាស័ក្តិ ដោយភ្ជាប់ជាមួយលិខិតបញ្ជាបេសកកម្មរបស់អង្គភាពមានសមត្ថកិច្ចទទួលបន្ទុកជំរុញការអនុវត្តច្បាប់នេះ និងមានសិទ្ធិស្នើសុំកម្លាំងជំនួយពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីចូលរួមបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាស័ក្តិ របស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០១.-**

នៅក្នុងប្រតិបត្តិការជំរុញការអនុវត្តច្បាប់ ក្នុងករណីមានភស្តុតាងជាក់ស្តែង ឬតាមរយៈលទ្ធផលនៃការវិភាគហានិភ័យសមាសភាពចង្រៃចំពោះរាល់សកម្មភាព និងប្រតិបត្តិការ ដែលបង្កហានិភ័យនៃការរាលដាលឆ្លងសមាសភាពចង្រៃ ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចមានសិទ្ធិចាត់វិធានការផ្អាកបណ្តោះអាសន្នចំពោះសកម្មភាព ឬប្រតិបត្តិការនោះ ដើម្បីធ្វើរបាយការណ៍ជាបន្ទាន់ និងស្នើសុំសេចក្តីសម្រេចរបស់ប្រធានអង្គភាពមានសមត្ថកិច្ចសាមី ។

ផ្អែកតាមស្ថានភាពនិងទំហំនៃហានិភ័យចំពោះមុខ
ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសិទ្ធិចាត់វិធានការភូតគាមអនាម័យនៅនឹងកន្លែង រួមមានការធ្វើប្រព្រឹត្តិកម្មកម្ចាត់សមាសភាពចង្រៃ ការបំផ្លាញចោល ការប្រកាសជាទំនិញដែលមិនអាចលក់ចែកចាយបាន តាមការចាំបាច់។

**មាត្រា១០២.-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច មានសិទ្ធិធ្វើលិខិតតវ៉ាជាផ្លូវការ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលកំណត់ហេតុត្រួតពិនិត្យរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច។

រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់តាំងយន្តការស្រាវជ្រាវចំពោះករណីតវ៉ាលើការចាត់វិធានការរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ និងត្រូវចេញសេចក្ដីសម្រេចលើករណីតវ៉ានោះ នៅក្នុងរយៈពេលមិនលើសពី៦០(ហុកសិប)ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលលិខិតតវ៉ា។

ក្នុងករណីបុគ្គលនោះ មិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បុគ្គលនោះមានសិទ្ធិធ្វើលិខិតតវ៉ាទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬធ្វើបណ្ដឹងទៅតុលាការតាមនីតិវិធី។

**មាត្រា១០៣.-**

ក្នុងករណីរូបវន្តបុគ្គលឬនីតិបុគ្គលធ្វើប្រតិបត្តិការពាក់ព័ន្ធក្នុងក្របខណ្ឌនៃវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យ ដោយបង្កការរាលដាលឆ្លង និងការរាតត្បាតពីសមាសភាពចង្រៃ ដែលបង្កគ្រោះថ្នាក់ចំពោះប្រព័ន្ធអេក្យូឡូស៊ីបរិស្ថានរួមនៃតំបន់ផលិតកម្មកសិកម្មនិងនាំមកនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រយោជន៍សាធារណៈនិងសហគមន៍មូលដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិធ្វើបណ្ដឹងទាមទារសំណង ចំពោះបុគ្គលដែលប្រព្រឹត្តល្មើស។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវវាយតម្លៃចំពោះផលប៉ះពាល់ និងទំហំនៃការខូចខាត សម្រាប់ការទាមទារសំណងចំពោះបុគ្គលដែលប្រព្រឹត្តល្មើស ឬក្នុងករណីចាំបាច់

ត្រូវមានការចូលរួមវាយតម្លៃដោយតំណាងអន្តរក្រសួងពាក់ព័ន្ធតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ចំណាយលើដំណើរការវាយតម្លៃផលប៉ះពាល់ និងទំហំនៃការខូចខាត គឺជាបន្ទុករបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើស ដោយត្រូវរួមបញ្ចូលនៅក្នុងប្រាក់សំណងការខូចខាតដែលត្រូវទាមទារ។

**មាត្រា១០៤.-**

នីតិវិធី និងសំណុំបែបបទសម្រាប់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យប្រើប្រាស់ នៅក្នុងការអនុវត្តច្បាប់ ត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី១១
## ទោសប្បញ្ញត្តិ

**មាត្រា១០៥.-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមានបទបញ្ជាឱ្យកែកំហុស ការដកហូតឬការព្យួរវិញ្ញាបនបត្រឬលិខិតអនុញ្ញាតពាក់ព័ន្ធ ការពិន័យអន្តរការណ៍ សំណងការខូចខាត និងទោសព្រហ្មទណ្ឌ។

**មាត្រា១០៦.-**

បទបញ្ជាឱ្យកែកំហុស ការព្យួរឬការដកហូតវិញ្ញាបនបត្រឬលិខិតអនុញ្ញាតពាក់ព័ន្ធ ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការអនុវត្តពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចនៃអង្គភាពជាតិការពាររុក្ខជាតិ។

**មាត្រា១០៧.-**

ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចនៃអង្គភាពជាតិការពាររុក្ខជាតិមានសិទ្ធិអនុវត្តពិន័យអន្តរការណ៍ លើបទល្មើសដូចមានចែងក្នុងមាត្រា១១២ មាត្រា១១៣ និងមាត្រា១១៤ នៃច្បាប់នេះ។

ការពិន័យអន្តរការណ៍អាចអនុវត្តបានក្នុងករណីជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។ករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងនៃបទល្មើស ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

នីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា១០៨.-

នៅក្នុងប្រតិបត្តិការជំរុញការអនុវត្តច្បាប់ ក្នុងករណីមិនស្គាល់អត្តសញ្ញាណជនល្មើស ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច ត្រូវចេញសេចក្តីជូនដំណឹងចំនួន០៣(បី)លើក ដើម្បីឱ្យជនប្រព្រឹត្តល្មើសចូលមកបង្ហាញខ្លួនដោះស្រាយ បទល្មើសនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃម្តង ក្រោយកាលបរិច្ឆេទចេញសេចក្តីជូនដំណឹង។

ក្នុងករណីជនល្មើសមិនបង្ហាញខ្លួន ឬមិនព្រមដោះស្រាយបទល្មើសតាមនីតិវិធី ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច ត្រូវស្នើសុំព្រះរាជអាជ្ញារឹបអូសវត្ថុតាងនៃបទល្មើសជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោលតាមវិធានការភូតគាមអនាម័យ។ជនដែលមានប្រយោជន៍ពាក់ព័ន្ធនឹងមធ្យោបាយ គ្រឿងចក្រ សម្ភារបរិក្ខា ដែលជាវត្ថុតាងជំនួយក្នុងការប្រព្រឹត្តិបទល្មើសមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទៅតុលាការរដ្ឋបាលវេណី។

## មាត្រា១០៩.-

វត្ថុតាងនៃបទល្មើសដែលមានចែងក្នុងច្បាប់នេះ រួមមាន៖ ធនធានរុក្ខជាតិ រុក្ខជាតិផលិតផលរុក្ខជាតិ ផលិតផលការពាររុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀតដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស ព្រមទាំងមធ្យោបាយដឹកជញ្ជូន មធ្យោបាយផ្ទុកនិងសម្ភារបរិក្ខាផ្សេងទៀតដែលប្រើប្រាស់ជាជំនួយក្នុងការប្រព្រឹត្តបទល្មើស។

ករណីបទល្មើសដែលបានដោះស្រាយរួចតាមរយៈការសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬតាមរយៈសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ វត្ថុតាងពិតប្រាកដនៃបទល្មើស ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវចាត់ចែងដូចខាងក្រោម៖

១-អាចប្រគល់ជូនម្ចាស់ដើមវិញ
ក្នុងករណីលទ្ធផលនៃការត្រួតពិនិត្យនិងការវិភាគហានិភ័យសមាសភាពចង្រៃ
ដោយភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច ដែល
បញ្ជាក់ថាគ្មានសញ្ញាវត្តមានសមាសភាពចង្រៃ។

២-ក្នុងករណីលទ្ធផលបញ្ជាក់ថាមានសញ្ញាវត្តមានសមាសភាពចង្រៃ
ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចត្រូវចាត់វិធានការភូតគាមអនាម័យ
ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ការសម្រេចអំពីវត្ថុតាងដែលចាប់យក ឬត្រូវរឹបអូស
ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## មាត្រា១១០.-

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យដោយតុលាការ និងប្រាក់ចំណូលពីការលក់វត្ថុតាង
ដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ត្រូវបង់ចូលថវិកាជាតិ។

រាជរដ្ឋាភិបាលផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលបានចូលរួមក្នុង
ករណីជំរុញការអនុវត្តច្បាប់នេះ
ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## មាត្រា១១១.-

ត្រូវទទួលបទបញ្ជាឱ្យកែកំហុសជាលាយលក្ខណ៍អក្សរចំនួន៣(បី)លើក
ដោយទទួលការអប់រំពីអង្គភាពជាតិការពាររុក្ខជាតិមានសមត្ថកិច្ច
ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលម្ចាស់ កសិដ្ឋាន
ឬប្រតិបត្តិករដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងរុក្ខជាតិ
ផលិតផលរុក្ខជាតិនិងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត
ដែលប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម៖

១-មិនបានរាយការណ៍
ឬជូនដំណឹងបន្ទាន់មកអង្គភាពជាតិការពាររុក្ខជាតិមានសមត្ថកិច្ចដែលនៅជិតបំផុត
អំពីករណីកើតមានវត្តមានសមាសភាពចង្រៃ ឬការរាលដាលឆ្លងសមាសភាពចង្រៃ
ឬការផ្ទុះឡើងសមាសភាពចង្រៃលើរុក្ខជាតិ និងធនធានរុក្ខជាតិ នៅក្នុង កសិដ្ឋានសាមី
ដោយទុកឱ្យបង្កការរាលដាលឆ្លង ការបំផ្លាញ

ឬការខូចខាតផលប្រយោជន៍សាធារណៈឬផលប្រយោជន៍របស់ជនដទៃ
នៅក្នុងមូលដ្ឋានសាមី។

២-
បដិសេធមិនអនុវត្តតាមការអប់រំណែនាំរបស់អង្គភាពជាតិការពាររុក្ខជាតិមានសមត្ថកិច្ចស្ដី
ពីគោលការណ៍សម្រាប់វិធានការការពាររុក្ខជាតិ
ឬបដិសេធមិនចូលរួមចលនាមហាជនក្នុងមូលដ្ឋាន
ដើម្បីសហការចាត់វិធានការទប់ស្កាត់ការរាលដាលឆ្លង និងការកម្ចាត់
សមាសភាពចង្រៃ ដែលបំផ្លាញរុក្ខជាតិនិងធនធានរុក្ខជាតិនៅក្នុងមូលដ្ឋានសាមី។

៣-បដិសេធ
មិនព្រមអនុវត្តតាមសេចក្ដីជូនដំណឹងរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថ
កិច្ច ដែលតម្រូវឱ្យចាត់វិធានការបន្ទាន់ដើម្បីទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃ
កម្ចាត់សមាសភាពចង្រៃ ឬអនុវត្តវិធានការភូតគាមអនាម័យក្នុងកសិដ្ឋានរបស់ខ្លួន។

៤-បដិសេធមិនព្រមឆ្លើយសំណួរ ឬមិនបង្កលក្ខណៈចំពោះការត្រួតពិនិត្យភូតគាម
អនាម័យឬមិនសហការក្នុងការអនុវត្តវិធានការភូតគាមអនាម័យឬការបំពេញភារកិច្ចអនុវត្តច្បាប់
របស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច។

៥-មិនអនុវត្តកាតព្វកិច្ចជាម្ចាស់ធនធានរុក្ខជាតិ
ម្ចាស់ទីតាំងគ្រប់ប្រភេទដែលពាក់ព័ន្ធរុក្ខជាតិនិងផលិតផលរុក្ខជាតិ
និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
ដែលត្រូវអនុវត្តវិធានការភូតគាមអនាម័យ ស្របតាមច្បាប់នេះ ។

ក្នុងករណីមិនរាងចាល បុគ្គលដែលប្រព្រឹត្តអំពើខាងលើ
ត្រូវទទួលខុសត្រូវសំណងការខូចខាត
ឬលើព្យសនកម្មដែលបណ្ដាលមកពីអំពើប្រព្រឹត្តរបស់ខ្លួន។

## មាត្រា១១២.-

ត្រូវទទួលពិន័យអន្តរការណ៍ដោយភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច
ជាប្រាក់ចំនួនពី១ ០០០ ០០០(មួយលាន)រៀល ទៅ៥ ០០០ ០០០ (ប្រាំលាន)រៀល
ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលណាដែលធ្វើសេវាកម្មក្នុងក្របខណ្ឌនៃប្រព័ន្ធវិធានការការពាររុក្ខ
ជាតិឬវិធានការភូតគាមអនាម័យ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ដោយ
ប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម៖

១-គ្មានសៀវភៅកំណត់ត្រាសេវាកម្មការពាររុក្ខជាតិ និងភូតគាមអនាម័យ ឬគ្មាន

កំណត់ត្រាអំពីសកម្មភាព ឬទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការសេវាកម្ម ដែលតម្រូវដោយច្បាប់នេះ។

២-មិនអនុវត្តកាតព្វកិច្ចជាប្រតិបត្តិករ ដូចខាងក្រោម៖

២.១-មិនអនុវត្តលក្ខខណ្ឌ បទបញ្ជា និងរយៈពេលសុពលភាពដែលកំណត់ក្នុងវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។

២.២-មិនបានស្នើសុំការយល់ព្រមជាមុន ចំពោះការផ្ទេរសិទ្ធិកាន់កាប់វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតពាក់ព័ន្ធ។

២.៣-មិនទទួលខុសត្រូវលើរាល់ប្រតិបត្តិការរបស់សាខាចំណុះនិងសកម្មភាពរបស់និយោជិតរបស់ខ្លួន ដែលបង្កឱ្យមានអំពើល្មើស ឬការរំលោភលើបទប្បញ្ញត្តិនៃច្បាប់នេះ។

២.៤-មិនទទួលខុសត្រូវចំពោះការរាលដាលឆ្លងសមាសភាពចង្រៃឬចំពោះហានិភ័យគ្រោះថ្នាក់ផ្សេងទៀត ដែលកើតឡើងនៅក្នុងប្រតិបត្តិការពាក់ព័ន្ធ។

២.៥-គ្មានបុគ្គលិកបច្ចេកទេសដែលមានការទទួលស្គាល់ ដើម្បីទទួលខុសត្រូវជាអចិន្ត្រៃយ៍លើក្របខណ្ឌបច្ចេកទេស ក្នុងប្រតិបត្តិការផ្តល់សេវាកម្មពាក់ព័ន្ធ។

៣-មិនបានជូនដំណឹងឬធ្វើសេចក្តីប្រកាសជូនភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចនៅមាត់ច្រកទ្វារព្រំដែនពាក់ព័ន្ធ អំពីការនាំចូល ការនាំចេញ ឬការដឹកជញ្ជូនឆ្លងកាត់នូវទំនិញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ផ្សេងទៀត។

៤-ធ្លាប់បានទទួលទណ្ឌកម្មមិនរាងចាលដូចមានចែងក្នុងមាត្រា១១១ នៃច្បាប់នេះ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ទ្វេរដង ឬត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី។

## មាត្រា១១៣.-

ត្រូវទទួលពិន័យអន្តរការណ៍ដោយភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចជាប្រាក់ចំនួនពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន)រៀល ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម៖

១-ធ្វើសេវាកម្មការពាររុក្ខជាតិឬសេវាកម្មភូតគាមអនាម័យ ដោយគ្មានលិខិតអនុញ្ញាតក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ។

២-ធ្វើការកាន់កាប់ផលិតផលការពាររុក្ខជាតិ ឬធ្វើសេវាកម្មការពាររុក្ខជាតិឬសេវាកម្មភូតគាមអនាម័យដោយប្រើផលិតផលការពាររុក្ខជាតិដែលមិនបានឆ្លងកាត់ដំណើរការសិក្សា វាយតម្លៃ ឬគ្មានសេចក្តីវាយតម្លៃរបស់អង្គភាពជាតិការពាររុក្ខជាតិមានសមត្ថកិច្ច។

៣-ជួលប្រើសេវាកម្ម ឬធ្វើការដឹកជញ្ជូនដោយផ្ទាល់នូវទំនិញ រុក្ខជាតិ ផលិតផលរុក្ខជាតិនិងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ដោយល្មើសនឹងវិធានការភូតគាមអនាម័យ និងបទបញ្ជាហាមឃាត់នៅក្នុងតំបន់ដែលបានប្រកាសជាតំបន់រាលដាលឆ្លងសមាសភាពចង្រៃ ឬតំបន់ហាមឃាត់។

៤-ជួល ប្រើសេវាកម្ម ឬធ្វើការផ្សព្វផ្សាយដោយផ្ទាល់អំពីការអនុវត្តវិធានការការពាររុក្ខជាតិឬវិធានការភូតគាមអនាម័យអំពីការប្រើប្រាស់ផលិតផលការពាររុក្ខជាតិនិងផលិតផលផ្សេងទៀតដែលមានប្រសិទ្ធភាពក្នុងការអនុវត្តវិធានការការពាររុក្ខជាតិ ដោយគ្មានសេចក្តីវាយតម្លៃរបស់អង្គភាពជាតិការពាររុក្ខជាតិ ឬល្មើសនឹងលក្ខខណ្ឌតម្រូវក្រោមបទប្បញ្ញត្តិនិងនីតិវិធី នៃច្បាប់នេះ។

៥-មិនព្រមបញ្ឈប់ប្រតិបត្តិការផ្តល់សេវាកម្មពាក់ព័ន្ធ ក្នុងក្របខណ្ឌនៃប្រព័ន្ធវិធានការការពាររុក្ខជាតិនិងវិធានការភូតគាមអនាម័យដោយល្មើសនឹងសេចក្តីសម្រេចផ្អាកជាបណ្តោះអាសន្នរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច។

៦-ធ្វើចរាចរណ៍ទំនិញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលសំបកវេចខ្ចប់ ឬមធ្យោបាយផ្ទុកទំនិញ ដាច់ខ្សែសុវត្ថិភាព ដោយគ្មានការអនុញ្ញាត ការត្រួតពិនិត្យឡើងវិញ និងការចាត់វិធានការភូតគាមអនាម័យឡើងវិញពីភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ច។

៧-ជួល ប្រើសេវាកម្ម ឬដឹកជញ្ជូនដោយផ្ទាល់នូវ ទំនិញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ

ដោយគេចវេសពីការបំពេញកាតព្វកិច្ចក្នុងការការពារសន្តិសុខភូតគាមអនាម័យ បន្ទាប់ពីបានទទួលវិញ្ញាបនបត្រភូតគាមអនាម័យ។

៨-ដួល ប្រើសេវាកម្ម ឬដឹកជញ្ជូនដោយផ្ទាល់នូវ ទំនិញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលបង្កការរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃគ្រោះថ្នាក់នៅតាមផ្លូវដឹកជញ្ជូន។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ទ្វេរដង ឬត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី។

## មាត្រា១១៤.-

ត្រូវទទួលពិន័យអន្តរការណ៍ដោយភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យមានសមត្ថកិច្ចជាប្រាក់ចំនួនពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ២០ ០០០ ០០០ (ម្ភៃលាន)រៀល ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម៖

១-ដួល ប្រើសេវាកម្ម ឬធ្វើការផ្សព្វផ្សាយដោយផ្ទាល់នូវព័ត៌មានអំពីសមាសភាពចង្រៃគ្រប់ប្រភេទ ឬព័ត៌មានស្ដីពីការផ្ទុះឡើង ឬការរាលដាលឆ្លងសមាសភាពចង្រៃ ដោយគ្មានការអនុញ្ញាត ឬផ្ទុយពីព័ត៌មានដែលបញ្ចេញដោយអង្គភាពជាតិការពាររុក្ខជាតិ។

២-ធ្វើការនាំចូល នាំចេញទំនិញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដោយគ្មានវិញ្ញាបនបត្រភូតគាមអនាម័យឬផ្ទុយពីលក្ខខណ្ឌតម្រូវក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

៣-កាន់កាប់ទុកជាមុន ឬធ្វើជំនួញលើឯកសារវិញ្ញាបនបត្រភូតគាមអនាម័យ ដោយគ្មានទំនិញឬមិនទាន់មានទំនិញគ្រប់គ្រាន់ សម្រាប់ការនាំចូល នាំចេញនូវទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលផ្ទុយពីលក្ខខណ្ឌតម្រូវក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

៤-ដួល ប្រើសេវាកម្ម ឬដឹកជញ្ជូនដោយផ្ទាល់ឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា នូវទំនិញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលបង្កឱ្យកើតមានហានិភ័យរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃគ្រោះ ថ្នាក់។

៥-ធ្វើពាណិជ្ជកម្ម ឬធ្វើការដាំដុះប្រភេទដំណាំ ដែលកំណត់ក្នុងបញ្ជីប្រភេទដំណាំស្ថិតក្រោមលក្ខខណ្ឌដោយគ្មានលិខិតអនុញ្ញាតរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៦-ធ្វើផលិតកម្មដំណាំ ធ្វើការកែច្នៃ ធ្វើពាណិជ្ជកម្ម ធ្វើចរាចរណ៍លើទីផ្សារ និងដឹកជញ្ជូនគ្រប់រូបភាពនូវទំនិញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលបានដឹងថាមានវត្តមានសមាសភាពចង្រៃ ឬមានការរាលដាលឆ្លងសមាសភាពចង្រៃ។

៧-ធ្វើផលិតកម្មដំណាំ ដោយប្រព្រឹត្តល្មើសនឹងបទហាមឃាត់ក្នុងការអនុវត្តវិធានការការពាររុក្ខជាតិដែលបង្កគ្រោះថ្នាក់ចំពោះមនុស្ស សត្វ សត្វវធម្មជាតិ និងប្រព័ន្ធក្សេត្រ បរិស្ថាន។

៨-ប្រមូលផលិតផលដំណាំចេញពីកន្លែងដាំដុះ ដើម្បីធ្វើចរាចរណ៍លើទីផ្សារ ឬប្រើប្រាស់ជាអាហារសម្រាប់មនុស្ស ចំណីសត្វ ឬជាវត្ថុធាតុដើមក្នុងការផលិតកែច្នៃជាអាហារ ដោយមានសមាសភាគនៃសំណល់ថ្នាំកសិកម្មលើសពីកម្រិតស្តង់ដារអតិបរមា ឬផ្ទុកដោយសារជាតុបង្កផលប៉ះពាល់ចំពោះសុខភាព។

៩-ធ្វើការនាំចេញ ការនាំចូល ការរក្សាទុក ការដឹកជញ្ជូន ការតាំងលក់ និងការប្រើប្រាស់ពូជដំណាំ ដែលមានចម្លងសមាសភាពចង្រៃកម្រិតធ្ងន់ធ្ងរ ឬមានចម្លងសមាសភាពចង្រៃភូតគាមអនាម័យឬសមាសភាពចង្រៃជាប់បញ្ញត្តិ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ទ្វេរដង ឬត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី។

## មាត្រា១១៥.-

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ដល់៥(ប្រាំ)ឆ្នាំ និង/ឬ ត្រូវពិន័យជាប្រាក់ចំនួនពី២៥ ០០០ ០០០(ម្ភៃប្រាំលាន)រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន)រៀល ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយ ក្នុងចំណោមអំពើដូចខាងក្រោម៖

១-ធ្វើការដាំដុះ ការនាំចូល ការកាន់កាប់ ឬការចែកចាយនូវសព៌ាង្គកាយបង្កគ្រោះថ្នាក់រុក្ខជាតិចង្រៃ និងប្រភេទចំណូលថ្មីឈ្លានពាននៃរុក្ខជាតិឬសត្វ ដែលបង្កហានិភ័យរាតត្បាតចំពោះរុក្ខជាតិ ផលិតផលរុក្ខជាតិ និងប្រព័ន្ធក្សេត្របរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ធ្វើការបញ្ជូនសំណាកសមាសភាពចង្រៃទៅក្រៅប្រទេស ដែលបង្កហានិភ័យចំពោះផលប្រយោជន៍ជាតិ។

៣-លាតត្រដាងព័ត៌មានផ្លូវការ ឬព័ត៌មានសម្ងាត់ណាមួយ ពាក់ព័ន្ធសមាសភាពចង្រៃ ឬការផ្ទុះឡើងសមាសភាពចង្រៃ ដែលបង្កផលប៉ះពាល់ដល់សង្គម សេដ្ឋកិច្ចជាតិ។

៤-ធ្វើប្រតិបត្តិការពាក់ព័ន្ធវិធានការការពាររុក្ខជាតិនិងភូតគាមអនាម័យដោយចេតនាបង្កលក្ខណៈ ឬបង្កឱ្យមានការរាលដាលឆ្លងសមាសភាពចង្រៃណាមួយ ដូចមានចែងក្នុងបញ្ជីសមាសភាពចង្រៃហាមឃាត់ ដែលបង្កការខាតបង់ផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ ជនដទៃ។

៥-នាំចូលដោយចេតនាមកក្នុងព្រះរាជាណាចក្រកម្ពុជា នូវសមាសភាពចង្រៃណាមួយ ឬទំនិញដែលមានវត្តមានសមាសភាពចង្រៃ ឬមានហានិភ័យសមាសភាពចង្រៃ។

៦-បោះចោលដោយចេតនា ឬពង្រាយនូវសមាសភាពចង្រៃ ឬទំនិញជាប់សមាសភាពចង្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១១៦.-**

ត្រូវផ្តន្ទាទោសក្រោមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គល ដែលប្រព្រឹត្តិអំពើណាមួយ ក្នុងចំណោមអំពើដូចខាងក្រោម៖

១-ក្លែងវិញ្ញាបនបត្រភូតគាមអនាម័យ ក្លែងត្រាភូតគាមអនាម័យរបស់អង្គភាពជាតិការពាររុក្ខជាតិ ឬក្លែងលិខិតអនុញ្ញាតពាក់ព័ន្ធដែលប្រើប្រាស់ក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ។

២-ក្លែងលទ្ធផលវិភាគ លទ្ធផលពិសោធន៍សាកល្បង លទ្ធផលវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ លទ្ធផលវិភាគហានិភ័យសមាសភាពចង្រៃ ឬក្លែងសេចក្តីវាយតម្លៃបច្ចេកទេសរបស់អង្គភាពជាតិការពាររុក្ខជាតិ។

៣-លាក់បំបាំងវត្ថុតាងនៃបទល្មើស ដែលត្រូវចាប់យក ឬត្រូវរឹបអូស ឬត្រូវបំផ្លាញចោល។

៤-បំភាន់ព័ត៌មានឬទិន្នន័យ ផ្តល់ព័ត៌មានមិនពិត ផ្តល់ឯកសារក្លែងបន្លំ លុបចោលឬបំផ្លាញចោលនូវឯកសារជាភស្តុតាងដើម្បីបំពេញ លក្ខខណ្ឌតម្រូវនានាក្រោមបទប្បញ្ញត្តិនៃ ច្បាប់នេះ។

៥-គំរាមកំហែង បដិសេធមិនអនុវត្តច្បាប់ ប្រើប្រាស់សិទ្ធិអំណាចដោយរំលោភឬធ្វើឱ្យរាំងស្ទះ ចំពោះការបំពេញសមត្ថកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យភូតគាមអនាម័យ ស្របតាមច្បាប់នេះ។

**មាត្រា១១៧.-**

បន្ថែមលើទោសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា១១២ មាត្រា១១៣ មាត្រា១១៤ មាត្រា១១៥ និងមាត្រា១១៦នៃច្បាប់នេះ រូបវន្តបុគ្គលឬនីតិបុគ្គល ទោះជាចារីឬអ្នកសមគំនិតក្តីដែលបង្កផលប៉ះពាល់ដល់ផលប្រយោជន៍ឬទ្រព្យសម្បត្តិរបស់អ្នកដទៃឬទ្រព្យសម្បត្តិសាធារណៈ ដែលជាព្យសនកម្មបណ្តាលមកពីអំពើប្រព្រឹត្តរបស់ខ្លួន ត្រូវទទួលខុសត្រូវលើសំណងការខូចខាត ឬសំណងរដ្ឋប្បវេណី ស្របតាមច្បាប់ជាធរមាន។

## មាត្រា១១៨.-

នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបទល្មើសមិនរាងចាលដូចមានចែងក្នុងមាត្រា១១២ មាត្រា១១៣ និងមាត្រា១១៤ដែលសំណុំរឿងបានបញ្ជូនមកតុលាការ និងបទល្មើសដូចមានចែងក្នុងមាត្រា១១៥និងមាត្រា១១៦ នៃច្បាប់នេះ ដោយត្រូវពិន័យជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន)រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ស្របតាមមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌស្តីពីទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល។

ទោសបន្ថែមអាចត្រូវប្រកាសដូចខាងក្រោម៖

១-រឹបអូសវត្ថុតាងនៃបទល្មើស។

២-ហាមឃាត់ការប្រកបមុខរបរ ដែលពាក់ព័ន្ធវិស័យកសិកម្ម ក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ ឬត្រូវហាមឃាត់ជាស្ថាពរ។

៣-បិទគ្រឹះស្ថាន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

៤-ផ្សព្វផ្សាយសេចក្តីសម្រេចទណ្ឌកម្មនៅក្នុងសារព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយ។

## មាត្រា១១៩.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រា១១២ មាត្រា១១៣ មាត្រា១១៤មាត្រា១១៥ និងមាត្រា១១៦ នៃច្បាប់នេះអាចប្រឈមចំពោះការដកហូត ឬលុបចោល នូវវិញ្ញាបនបត្រឬលិខិតអនុញ្ញាតពាក់ព័ន្ធដែលបានចេញក្រោមបទប្បញ្ញត្តិនៃច្បាប់។

## មាត្រា១២០.-

មន្ត្រីរាជការមានសមត្ថកិច្ចអនុវត្តច្បាប់នេះ មន្ត្រីរាជការផ្សេងទៀត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលរំលោភលើសមត្ថកិច្ចរបស់ខ្លួន ឬប្រើសិទ្ធិអំណាច ឬសមគំនិតលាក់បំបាំងបទល្មើស និងបង្កឧបសគ្គដើម្បីរារាំងការអនុវត្តច្បាប់នេះ

ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមាន និងត្រូវប្រឈមចំពោះការទទួលទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ឬត្រូវទទួលខុសត្រូវលើសំណងរដ្ឋប្បវេណី ព្រមទាំងព្យសនកម្មផ្សេងទៀតដែល
បណ្ដាលមកពីអំពើប្រព្រឹត្តរបស់មន្ត្រីនោះ។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា១២១.-**

បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធការការពាររុក្ខជាតិនិងភូតគាមអនាម័យដែលកំពុងមានអានុភាពអនុវត្ត
ត្រូវបន្តអនុវត្តត្រឹមដែនគ្របដណ្ដប់ដែលមិនផ្ទុយជាមួយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ
រហូតដល់បទដ្ឋានគតិយុត្តថ្មីក្រោមច្បាប់នេះ ត្រូវបានជំនួស។

**មាត្រា១២២.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលកាន់កាប់វិញ្ញាបនបត្រឬលិខិតអនុញ្ញាតមានសុពលភាពក្នុងក្របខណ្ឌនៃការការពាររុក្ខជាតិនិងភូតគាមអនាម័យ នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបញ្ចប់ប្រតិបត្តិការពាក់ព័ន្ធរបស់ខ្លួន និងត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតជាថ្មីស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះនៅក្នុងរយៈពេលមិនលើសពី១២(ដប់ពីរ)ខែ
ដោយគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ
ឬនៅកាលបរិច្ឆេទចូលជាធរមាននៃបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រោមច្បាប់នេះ។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា១២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២៤.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី..........ខែ................ឆ្នាំ២០១

នាសម័យប្រជុំរដ្ឋសភាលើកទី........នីតិកាលទី........
រាជធានីភ្នំពេញ ថ្ងៃទី..........ខែ...........ឆ្នាំ២០១

# ឧបសម្ពន្ធនៃច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ

-----✿✿✿✷✿✿✿-----

## សទ្ទានុក្រម

**១- ការការពាររុក្ខជាតិ** (Plants Protection)

សំដៅដល់សកម្មភាព និងកិច្ចប្រតិបត្តិនៃការគ្រប់គ្រងសមាសភាពចង្រៃគ្រប់ប្រភេទ ដែលបំផ្លាញរុក្ខជាតិនិងផលដំណាំ តាមរយៈការទប់ស្កាត់ការបង្ក ការប្រមូលផ្តុំ ការរាលដាលឆ្លង និងការរាតត្បាតពីសំណាក់សមាសភាពចង្រៃ ព្រមទាំងការអនុវត្តវិធានការកម្ចាត់ ក្នុងគោលបំណងការពារធនធានរុក្ខជាតិ និងដើម្បីកាត់បន្ថយការខាតបង់នៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម និង កាត់បន្ថយផលប៉ះពាល់ចំពោះសង្គមសេដ្ឋកិច្ច។

**២- ការត្រួតពិនិត្យភូតគាមអនាម័យ** (Phytosanitary Inspection)

សំដៅដល់ការស្រាវជ្រាវ ការអង្កេត ការពិនិត្យ ការដកយកសំណាកមកធ្វើវិភាគ និងកំណត់អត្តសញ្ញាណកម្មសមាសភាពចង្រៃ ចំពោះទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីកំណត់នូវស្ថានភាពនៃការបំផ្លាញដោយសមាសភាពចង្រៃ។

**៣- ការធ្វើប្រព្រឹត្តកម្ម** (Treatment)

សំដៅដល់កិច្ចប្រតិបត្តិបច្ចេកទេសដើម្បីសម្លាប់ ធ្វើមិនឱ្យមានសកម្មភាព ឬយកសមាសភាព ចង្រៃចេញ ឬធ្វើឱ្យសមាសភាពចង្រៃបាត់សមត្ថភាពបន្តពូជ និងដើម្បីផ្តាច់ជីវិតសមាសភាពចង្រៃ។

**៤- ការវិភាគហានិភ័យសមាសភាពចង្រៃ** (Pest Risk Analysis)

សំដៅដល់ដំណើរការនៃការវាយតម្លៃ ដោយផ្អែកលើភស្តុតាងជីវសាស្ត្រ វិទ្យាសាស្ត្រ និងសេដ្ឋកិច្ច នៃសមាសភាពចង្រៃ ដើម្បីកំណត់សព៌ាង្គកាយណាមួយគឺជាសមាសភាពចង្រៃ ដែលត្រូវដាក់បញ្ញត្តិ និងត្រូវពង្រឹងនូវវិធានការភូតគាមអនាម័យកម្រិតណាមួយ ដើម្បីទប់ទល់។

**៥-ការធានាគុណភាព** (Quality Assurance)

សំដៅដល់ប្រព័ន្ធការងារចំរុះនៅក្នុងផលិតកម្មកសិកម្ម ដែលពាក់ព័ន្ធ៖ ការរៀបចំផែនការសម្រាប់ការធានាគុណភាព ការត្រួតពិនិត្យគុណភាព ការវាយតម្លៃគុណភាព កំណត់ត្រាគុណភាព និងការធ្វើឱ្យប្រសើរនូវគុណភាពផលិតផលកសិកម្ម និងផលិតផលការពាររុក្ខជាតិ ដើម្បីធានាថាផលិតផលទាំងនោះនិងបណ្ដាសេវាកម្មការពាររុក្ខជាតិ ឆ្លើយតបតាមស្តង់ដារកំណត់នៃគុណភាព ប្រកបដោយទំនុកចិត្ត។

**៦-ការអនុវត្តកសិកម្មល្អ** (Good Agricultural Practice "GAP ")

សំដៅដល់ប្រតិបត្តិការដាំដុះឬផលិតកម្មដំណាំគ្រប់ប្រភេទដែលអនុវត្តវិធានការការពាររុក្ខជាតិ ឬប្រើប្រាស់ផលិតផលការពាររុក្ខជាតិសមស្របតាមបច្ចេកទេស ក្រោមលក្ខខណ្ឌជាក់ស្តែងសម្រាប់គ្រប់គ្រងសមាសភាពចង្រៃប្រកបដោយប្រសិទ្ធភាព ដោយបន្សល់នូវសំណល់ថ្នាំកសិកម្ម ឬសារធាតុពុលបង្កគ្រោះថ្នាក់ចំពោះសុខភាព ក្នុងកម្រិតស្តង់ដារអប្បបរមា។

**៧-កម្រិតសំណល់អតិបរមា** (Maximum Residue Limit "MRL")

សំដៅដល់សមាសភាគឬកំហាប់អតិបរមាដែលអនុញ្ញាតដោយច្បាប់ឬទទួលស្គាល់ នៃសំណល់សារធាតុពុលដែលស្ថិតនៅក្នុងឬនៅលើស្បៀងអាហារ ផលិតផលកសិកម្មមានដើមកំណើតពីរុក្ខជាតិ ចំណីសត្វ ឬផលិតផលសត្វ ដែលបានដាំដុះឬចិញ្ចឹម ដែលជាលទ្ធផលនៃការប្រើប្រាស់សារធាតុគីមី ឬសារធាតុបង្កគ្រោះថ្នាក់ចំពោះសុខភាព។

**៨-គ្រោះបន្ទាន់ភូតគាមអនាម័យ** (Phytosanitary Emergency)

សំដៅដល់វិធានការភូតគាមអនាម័យ ដែលបានបង្កើតឡើង និងអនុវត្តដើម្បីឆ្លើយតបបន្ទាន់ចំពោះស្ថានភាពភូតគាមអនាម័យបន្ទាន់ថ្មីណាមួយ ឬជាស្ថានភាពមិនបានរំពឹងទុក ដែលអាចជាវិធានការបណ្តោះអាសន្ន ឬជាវិធានការពេញលេញ។

**៩-តំបន់គ្មានសមាសភាពចង្រៃ** (Pest Free Area)

សំដៅដល់តំបន់ដែលគ្មានវត្តមានសមាសភាពចង្រៃជាក់លាក់ណាមួយកើតឡើង តាមរយៈការបង្ហាញភស្តុតាងវិទ្យាសាស្ត្រ ហើយដែលលក្ខខណ្ឌនេះត្រូវបានរក្សាជាផ្លូវការ។

**១០-ទំនិញបញ្ញើ** (Consignment)

សំដៅដល់បរិមាណរុក្ខជាតិ ផលិតរុក្ខជាតិ និង/ឬទំនិញផ្សេងទៀតមួយមុខ ឬ ច្រើនមុខ ដែលធ្វើចរាចរណ៍ពីប្រទេសមួយទៅប្រទេសមួយទៀត ស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃការត្រួតពិនិត្យភូតគាមអនាម័យ និងការបញ្ជាក់ស្ថានភាពភូតគាមអនាម័យ តាមរយៈវិញ្ញាបនបត្រ ភូតគាមអនាម័យ រួមគ្នាតែមួយច្បាប់ ។

**១១-ធនធានរុក្ខជាតិ** (Plants Resources)

សំដៅដល់រុក្ខជាតិគ្រប់លំដាប់ថ្នាក់ ប្រភេទ ពូជ អំបូរសម្ព័ន្ធ និងទម្រង់ជីវសាស្រ្ត នៃប្រព័ន្ធចំណាត់ថ្នាក់រុក្ខជាតិសកល។ ដោយផ្អែកតាមប្រភពកំណើត ការបន្តពូជ និងដែនចំណុះ ធនធានរុក្ខជាតិត្រូវបានរួមបញ្ចូលនូវបណ្តារុក្ខជាតិដែលមានប្រភពកំណើតនិងការបន្តពូជដោយធម្មជាតិ និងបណ្តារុក្ខជាតិដែលមានប្រភពកំណើតពីការបង្កាត់ពូជដោយសិប្បនិម្មិត្តតាមគ្រប់បច្ចេកវិទ្យាសេនេទិច ឬមានប្រភពពីការដាំដុះ ការធ្វើពហុកម្ម ឬផលិតកម្មដំណាំ។

**១២-នីតិវិធីភូតគាមអនាម័យ** (Phytosanitary Procedure )

សំដៅដល់វិធីសាស្រ្តផ្លូវការ សម្រាប់ការអនុវត្តវិធានការភូតគាមអនាម័យ រួមមាន ការត្រួតពិនិត្យ ការធ្វើតេស្ត ការអង្កេតឃ្លាំមើល ឬការធ្វើប្រព្រឹត្តកម្មទាក់ទងទៅនឹងសមាសភាពចង្រៃដាប់បញ្ញត្តិ។

**១៣-បញ្ជរជាតិភូតគាមអនាម័យ** (National Phytosanitary Clearing House)

សំដៅដល់ចំណុចការងារឬមណ្ឌលទំនាក់ទំនងថ្នាក់ជាតិ ដែលគ្រប់គ្រង រក្សាទុក និងចែកចាយប្រព័ន្ធព័ត៌មាននិងមូលដ្ឋានទិន្នន័យភូតគាមអនាម័យ តាមរយៈការតភ្ជាប់បណ្តាញការងាររបស់អង្គភាពជាតិការពាររុក្ខជាតិ ដែលបំពេញសមត្ថកិច្ចតាមបណ្តាទីកន្លែង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**១៤-ប្រភេទចំណូលថ្មីឈ្លានពាន** (Alien Invasive  Specie)

សំដៅដល់បណ្តាប្រភេទឬអំបូរសម្ព័ន្ធនៃប្រភេទរុក្ខជាតិឬសត្វដែលបានចូលមកក្នុងមជ្ឈដ្ឋានថ្មីក្រៅដែនរប៉ាយធម្មតារបស់វាក្នុងអតីតកាលឬបច្ចុប្បន្ន ដោយបង្កការរាលដាល ការរាតត្បាត និងធ្វើអាណានិគមលើលំនៅដ្ឋានដើមរបស់សហគមន៍រុក្ខជាតិដើម ។ ប្រភេទចំណូលថ្មីឈ្លានពាន រួមបញ្ចូលនូវផ្នែកទាំងឡាយនៃអង្គបន្តពូជ(Gemplasm) កាម៉ែត គ្រាប់ ស៊ុត អង្គពហុកម្មរុក្ខជាតិ (Propagules) ឬផ្នែកផ្សេងៗនៃសរីរាង្គបណ្តាប្រភេទទាំងនេះ ដែលអាចរស់ឡើងវិញ និងធ្វើការបន្តពូជជាបន្តបន្ទាប់ និងបង្កការរាតត្បាត។

**១៥-ប្រភេទរុក្ខជាតិស្ថិតក្រោមលក្ខខណ្ឌ** (Restricted Crops)

សំដៅដល់ប្រភេទឬពូជដំណាំដែលមានសារៈសំខាន់នៅក្នុងការប្រើប្រាស់សម្រាប់ផលិតកម្មឱសថ វេជ្ជសាស្ត្រព្យាបាលជម្ងឺ ឬមានសារៈសំខាន់សម្រាប់ការប្រើប្រាស់នៅក្នុង បច្ចេកវិទ្យាជាក់លាក់ណាមួយ ប៉ុន្តែប្រភេទរុក្ខជាតិឬដំណាំទាំងនោះអាចមានហានិភ័យគ្រោះថ្នាក់ចំពោះមនុស្ស សត្វ និងបរិស្ថាន។ ប្រភេទរុក្ខជាតិស្ថិតក្រោមលក្ខខណ្ឌអាចអនុញ្ញាតឱ្យធ្វើការដាំដុះសម្រាប់ការប្រើប្រាស់ដែលមានសារៈសំខាន់ជាក់លាក់ ដូចមានចែងក្នុងច្បាប់នេះ។

**១៦-ផលិតផលរុក្ខជាតិ** (Plants Product)

សំដៅដល់ផលិតផលដែលមានដើមកំណើតពីរុក្ខជាតិ ដែលមិនទាន់កែច្នៃ ពាក់កណ្តាលកែច្នៃ រួមទាំងផលិតផលឈើ ផលិតផលឈើកែច្នៃ អនុផលព្រៃឈើ និងផលិតផលវារីរុក្ខជាតិ ឬផលិតផលផ្សេងទៀតដែលមានដើមកំណើតពីរុក្ខជាតិគ្រប់ប្រភេទ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ។

**១៧-ផលិតផលការពាររុក្ខជាតិ** (Plants Protection Product)

សំដៅដល់សារធាតុសកម្មគីមីមួយឬច្រើន ភ្នាក់ងារជីវសាស្ត្រ(Biological Control Agent) ភ្នាក់ងារមីក្រូជីវសាស្ត្រ(Microbial) ភ្នាក់ងារជីវៈគីមី(Semi chemical) សពាង្គកាយ(Organism) ឬសារធាតុសពាង្គកាយកែសម្រួលហ្សែន(Genetic Modified Organism) ដែលត្រូវបានប្រើប្រាស់ជាផលិតផលការពាររុក្ខជាតិក្នុងគោលបំណងការការពាររុក្ខជាតិប្រឆាំងសពាង្គកាយហាមឃាត់ទាំងអស់ ប្រឆាំងនឹងការឃាយី និងការរាតត្បាតពីសំណាក់សមាសភាពចង្រៃ ការទប់ស្កាត់ផលប៉ះពាល់ដល់ដំណើរលូតលាស់របស់រុក្ខជាតិ ការរក្សាទុកផលិតផលរុក្ខជាតិ ការកម្ចាត់រុក្ខជាតិចង្រៃ ការបណ្តេញ ឬការសម្លាប់សមាសភាពចង្រៃ ការកម្ចាត់ភ្នាក់ងារចម្លងជំងឺរុក្ខជាតិ ជំរុញការលូតលាស់របស់រុក្ខជាតិ កែសម្រួលមុខងារសរីរសាស្ត្រ របស់រុក្ខជាតិ បង្កើនផលិតភាពនិងទិន្នផលដំណាំសម្រាប់ការគ្រប់គ្រងគុណភាពដី និងសម្រាប់ថែរក្សាគុណភាពឈើនិងផលិតផលឈើកែច្នៃ។

**១៨-ភូតគាមសមាសភាពចង្រៃ** (Plants Pest)

សំដៅដល់សមាសភាពចង្រៃគ្រប់ប្រភេទដែលមានវត្តមាន និងឃាយី ឬរាតត្បាតចំពោះធនធានរុក្ខជាតិ រុក្ខជាតិ ផលិតផលរុក្ខជាតិ ឬផលិតផលផ្សេងទៀតដែលមានដើមកំណើតពីរុក្ខជាតិ។

**១៩-ភូតគាមអនាម័យ** (Phytosanitary /Plants Quarantine)

សំដៅដល់គ្រប់សកម្មភាពដែលបង្កើតឡើងដើម្បីបង្ការឬទប់ស្កាត់ការបង្ក និង/ឬការរាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬដើម្បីធានាដល់ការកម្ចាត់សមាសភាពចង្រៃ ជាស្ថាពរ។

**២០-រុក្ខជាតិ** (Plants)

សំដៅដល់រុក្ខជាតិនៃប្រភេទមួយជាក់លាក់ ទោះបង្កកំណើតដោយធម្មជាតិ ដោយសិប្បនិមិត្ត ឬជាដំណាំក្តី រួមជាមួយបំណែករបស់វា (គ្រាប់ពូជ ឬស មើម ដើម សំបក មែក ស្លឹក ថ្នាំង ផ្កា ផ្លែ ។ល។) និងអង្គបង្កកំណើតរុក្ខជាតិ ឬរូបធាតុសេនេទិចរុក្ខជាតិ ព្រមទាំងសំណាករុក្ខជាតិនៅគ្រប់វគ្គលូតលាស់នៃគ្រប់ប្រភេទ ពូជ និងអំបូរសម្ព័ន្ធ ដែលបានរាប់បញ្ចូល ក្រោមចំណាត់ថ្នាក់នៃធនធានរុក្ខជាតិ។

**២១-លក្ខខណ្ឌតម្រូវភូតគាមអនាម័យ**( Phytosanitary Requirement)

សំដៅដល់លក្ខខណ្ឌតម្រូវរបស់សមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនីមួយៗក្នុងគោលបំណងទប់ស្កាត់ការបង្ក ការរាលដាលឆ្លងចូលមកក្នុងប្រទេស នូវសមាសភាពចង្រៃតាមរយៈសកម្មភាពនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ។

**២២-ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ**(Quarantine Goods)

សំដៅដល់រាល់រុក្ខជាតិ ផលិតផលរុក្ខជាតិ និងវត្ថុ ឬសម្ភារជាប់បញ្ញត្តិផ្សេងទៀត( Regulated Articles/Materials) ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ រួមមាន៖ ឃ្លាំង ឬកន្លែងរក្សាទុក សម្ភារវេចខ្ចប់ កំណល់ទ្រនាប់ មធ្យោបាយដឹកជញ្ជូន មធ្យោបាយផ្ទុក ដីឬបំណែកដីដែលជាប់ជាមួយឬសឬជាមួយផ្នែកណាមួយនៃរុក្ខជាតិ ល្បាយសារធាតុរ៉ែនិងសរីរាង្គដែលទ្រទ្រង់រុក្ខជាតិ សមាសភាពចង្រៃដែលរស់ឬងាប់ ឬសពាង្គកាយមានប្រយោជន៍ និងរាល់សពាង្គកាយដែលមានសមត្ថភាពចម្លងការរាលដាលសមាសភាពចង្រៃ និងវត្ថុផ្សេងទៀតដែលមិនមានប្រភពដើមពីរុក្ខជាតិ ប៉ុន្តែអាចបង្កើតនូវជម្រកនៃសមាសភាពចង្រៃ

នៅក្នុងសកម្មភាពពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ការដឹកជញ្ជូនឆ្លងកាត់ ឬចរាចរណ៍ក្នុងស្រុក។

**២៣-វិញ្ញាបនបត្រភូតគាមអនាម័យ** (Phytosanitary Certificate)

សំដៅដល់វិញ្ញាបនបត្រដែលចេញដោយអង្គភាពជាតិការពាររុក្ខជាតិ នៃអគ្គនាយកដ្ឋានកសិកម្ម បន្ទាប់ពីបានធ្វើការវិភាគហានិភ័យសមាសភាពចង្រៃលើមុខទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ រួមមាន វិញ្ញាបនបត្រភូតគាមអនាម័យនាំចូលសម្រាប់ការនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញ ឬការនាំចេញបន្តពីព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមគំរូដែលបានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីការការពារដំណាំ។

វិញ្ញាបនបត្រភូតគាមអនាម័យជាលក្ខខណ្ឌតម្រូវចាំបាច់ចំពោះប្រតិបត្តិករដែលធ្វើប្រតិបត្តិការនាំចូល នាំចេញ និងដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា នូវទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ។

**២៤-វិធានការភូតគាមអនាម័យ** (Phytosanitary Measure)

សំដៅដល់បណ្តាបទដ្ឋានគតិយុត្ត បទបញ្ជា ឬនីតិវិធីផ្លូវការ និងអន្តរាគមន៍ដែលអនុវត្តក្នុងគោលបំណងទប់ស្កាត់ការបង្ក ការជ្រៀតចូល និង/ឬ ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ ឬកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចដែលបង្កឡើងដោយសមាសភាពចង្រៃមិនមែនភូតគាមអនាម័យជាប់បញ្ញត្តិ។

**២៥-វិធានការចម្រុះគ្រប់គ្រងដំណាំ** (Integrated Pest Management "IPM")

សំដៅដល់ប្រព័ន្ធគ្រប់គ្រងសមាសភាពចង្រៃនៅក្នុងផលិតកម្មដំណាំ ដោយប្រើប្រាស់បច្ចេកទេសសមស្របតាមស្ថានភាពតម្រូវ ដើម្បីកាត់បន្ថយវត្តមានសមាសភាពចង្រៃ និងរក្សាវានៅកម្រិតទាបបំផុតដែលមិនបង្កហានិភ័យចំពោះសេដ្ឋកិច្ច។

**២៦-សុវិធានបច្ចេកទេស** (Technical justification)

សំដៅដល់វិធានបច្ចេកទេសកែសម្រួលសមស្របឬដែលអាចអនុវត្តបាន ដោយផ្អែកលើការសន្និដ្ឋានទាញចេញពីលទ្ធផលនៃការវិភាគហានិភ័យសមាសភាពចង្រៃ តាមរយៈការត្រួតពិនិត្យ និងការវាយតម្លៃប្រៀបធៀបជាមួយព័ត៌មានវិទ្យាសាស្ត្រមូលដ្ឋានដែលមានស្រាប់។

**២៧-ស្បៀង** (Food)

សំដៅដល់ផលិតផលដំណាំ ឬកសិផលមានដើមកំណើតពីរុក្ខជាតិ អនុផលព្រៃឈើ ឬផលិតផលជលផល ដែលជាផលិតផលស្រស់ឬផលិតផលកែច្នៃបឋម និងត្រូវយកទៅប្រើប្រាស់ ឬកែច្នៃបន្ថែមធ្វើជាអាហាររបស់មនុស្ស ឬជាចំណីសត្វ។

**២៨-ស្ថានីយភូតគាមចត្តាឡីសក័**(Plants Quarantine Station)

សំដៅដល់ស្ថានីយផ្លូវការដែលត្រូវបង្កើតដោយច្បាប់នេះ សម្រាប់ការរក្សាទុករុក្ខជាតិ ឬផលិតផលរុក្ខជាតិ ក្នុងការបង្ខាំងទុកភូតគាមអនាម័យ ដើម្បីអង្កេត បន្តស្រាវជ្រាវ ធ្វើតេស្ត ឬធ្វើប្រព្រឹត្តកម្ម។

**២៩-សន្តិសុខភូតគាមអនាម័យ**(Phytosanitary Security)

សំដៅដល់ការថែទាំទំនិញបញ្ញើ និងការបង្ការការចម្លងសមាសភាពចង្រៃ និងការធ្វើឱ្យកខ្វក់ដោយសមាសភាពចង្រៃជាប់បញ្ញត្តិចំពោះទំនិញបញ្ញើ តាមរយៈការអនុវត្តវិធានការភូតគាមអនាម័យសមស្រប។

**៣០-សមាសភាពចង្រៃភូតគាមអនាម័យ** (Quarantine Pest)

សំដៅដល់សមាសភាពចង្រៃដែលមិនធ្លាប់មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមាននៅទីកន្លែងណាមួយជាក់លាក់ ប៉ុន្តែមិនទាន់មានការរាលដាលធ្លង ហើយត្រូវបាននិងកំពុងមានវិធានការកម្ចាត់ ឬបានធ្វើការកម្ចាត់ជាស្ថាពរ។

**៣១-សមាសភាពចង្រៃជាប់បញ្ញត្តិ** (Regulated pest)

សំដៅដល់សមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃមិនមែនភូតគាមអនាម័យជាប់បញ្ញត្តិ។

**៣២-សមាសភាពចង្រៃមិនមែនភូតគាមអនាម័យ ជាប់បញ្ញត្តិ**

(Regulated non-quarantine pest)

សំដៅដល់សមាសភាពចង្រៃមិនមែនភូតគាមអនាម័យ ដែលមានវត្តមាននៅក្នុងរុក្ខជាតិសម្រាប់ការដាំដុះ និងមានឥទ្ធិពលចំពោះគោលបំណងប្រើប្រាស់រុក្ខជាតិទាំងនោះ ដោយបង្កផលប៉ះពាល់សេដ្ឋកិច្ចដែលមិនអាចទទួលយកបាន និងជាមូលហេតុដែលភាគីប្រទេសនាំចូលបានកំណត់ឱ្យជាប់បញ្ញត្តិនៅក្នុងដែនដីរបស់ខ្លួន។

**៣៣-សត្រូវធម្មជាតិ** (Natural enemy)

សំដៅដល់សត្វល្អិតកាយដែលរស់នៅតាមរយៈការលេះបង់ចំណីនិងជីវិតរបស់សត្វល្អិតកាយផ្សេងទៀត នៅក្នុងលំនៅដ្ឋានធម្មជាតិរបស់វា ដែលអាចជួយកម្រិតប្រជាករសត្វល្អិតកាយនោះ។ សត្វល្អិតកាយទាំងនោះរួមមាន ភ្នាក់ងារបង្កជំងឺរុក្ខជាតិ ប៉ារ៉ាស៊ីតូអ៊ីត ប៉ារ៉ាស៊ីត និងពពួករុក្ខជាតិមំសាហំ ដូចជា រុក្ខជាតិស៊ីសត្វ ឬរុក្ខជាតិស៊ីរុក្ខជាតិ។

**៣៤-សមាសភាពចង្រៃ** (Pest)

សំដៅដល់រាល់ប្រភេទ ពូជ ឬស្រឡាយផ្សេងៗនៃសត្វល្អិតកាយ មីក្រូសត្វល្អិតកាយ សត្វល្អិតកាយកែសម្រួលហ្សែនរស់នៃរុក្ខជាតិ សត្វ ឬភ្នាក់ងារបង្កជំងឺ ដែលត្រូវបានកំណត់ថាជាប្រភេទចង្រៃ ដែលយាយីនិងរាតត្បាតចំពោះរុក្ខជាតិ និងធនធានរុក្ខជាតិគ្រប់ប្រភេទ។ សមាសភាពចង្រៃត្រូវបានរួមបញ្ចូលផងដែរនូវប្រភេទថ្មីឈ្លានពាន(Invasive Alien Species) ឬ សត្វល្អិតកាយបង្កគ្រោះថ្នាក់ (Harmful Organism) នៃរុក្ខជាតិឬសត្វ ជាប្រភេទស្ថិតនៅក្រៅដែនរប៉ាយធម្មជាតិរបស់វាក្នុងអតីតកាលឬបច្ចុប្បន្ន ដែលធ្វើឱ្យអន្តរាយដល់ធនធានរុក្ខជាតិ ផលិតផលរុក្ខជាតិ ឬផលិតផលដំណាំគ្រប់ប្រភេទ។ បញ្ជីសមាសភាពចង្រៃសម្រាប់ការគ្រប់គ្រងភូតគាមអនាម័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះ។

**៣៥-សមាសភាពចង្រៃក្នុងស្រុក** (Endemic pest )

សំដៅដល់រាល់ប្រភេទ ពូជ ឬស្រឡាយផ្សេងៗ នៃរុក្ខជាតិ សត្វ ឬភ្នាក់ងារបង្កជំងឺដែលមានប្រភពកំណើត ឬដែនរប៉ាយធម្មជាតិស្ថិតនៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជា ដែលអាចធ្វើឱ្យអន្តរាយដល់រុក្ខជាតិ ឬផលិតផលរុក្ខជាតិ ឬផលិតផលដំណាំគ្រប់ប្រភេទ។

**៣៦-សមាសភាពចង្រៃបង្កគ្រោះថ្នាក់** (Dangerous pest)

សំដៅដល់សមាសភាពចង្រៃដែលបណ្តាល ឬអាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសង្គម សេដ្ឋកិច្ច ឬបំផ្លាញធ្ងន់ធ្ងរដល់ធនធានរុក្ខជាតិ។

**៣៧-អនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ** (IPPC)

សំដៅដល់អនុសញ្ញាអន្តរជាតិស្តីពីការពាររុក្ខជាតិ ដែលបានអនុម័តនៅក្នុងសម័យប្រជុំលើកទី៦ នៃសន្និសិទរបស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO)ទីក្រុងរ៉ូម នាខែវិច្ឆិកា ឆ្នាំ១៩៥១ និងត្រូវបានចូលជាធរមាននៅថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៥២ ដែលមានសមាជិកភាគីសរុប១៣៩រដ្ឋ ហើយត្រូវបានចុះបញ្ជីលេខ១៩៦៣

តម្កល់ទុកនៅអង្គការសហប្រជាជាតិ នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥២។ ព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ជារដ្ឋភាគីភ្ជាប់កាតព្វកិច្ច(Adherence State Party) ជាមួយអនុសញ្ញានេះ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥២ បន្ទាប់ពីអនុសញ្ញានេះត្រូវបានចូលជាធរមាន។ អនុសញ្ញាអន្តរជាតិស្តីពីការការពារ រុក្ខជាតិ ត្រូវបានចាប់ផ្តើមធ្វើវិសោធនកម្មអត្ថបទនៃអនុសញ្ញាក្នុងសម័យប្រជុំលើកទី២០ នៃ សន្និសិទរបស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO)ទីក្រុងរ៉ូមនាខែវិច្ឆិកាឆ្នាំ១៩៧៩ បន្ទាប់មកបានអនុម័តយល់ព្រមទាំងស្រុងលើអត្ថបទវិសោធនកម្ម នៅក្នុងសម័យប្រជុំលើក ទី២៩ នៃសន្និសិទរបស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO)ទីក្រុងរ៉ូម នាខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលមានសមាជិកភាគីចំនួន៩០រដ្ឋ បានផ្តល់លិខិតុបករណ៍យល់ព្រម។ ព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នបង្គោលថ្នាក់ជាតិអនុវត្តអនុសញ្ញានេះ បានផ្តល់លិខិតុបករណ៍យល់ព្រមតាមរយៈលិខិតលេខ៣៥៥០ MAFF ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥។

អនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិមានគោលបំណង ជានានូវសកម្មភាពរួមក្របខណ្ឌសកលប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរាលដាលឆ្លង ការបង្កនូវសមាសភាពចង្រៃចំពោះ រុក្ខជាតិ និងផលិតផលរុក្ខជាតិ និងដើម្បីជំរុញការចាត់វិធានការសមស្រប ដើម្បីគ្រប់គ្រងសមាសភាពចង្រៃ។ រដ្ឋជាប់កិច្ចសន្យាក្រោមអនុសញ្ញានេះ ត្រូវអនុម័តក្របខណ្ឌច្បាប់ បច្ចេកទេស និងរដ្ឋបាលកិច្ចដែលបានកំណត់នៅក្នុងអនុសញ្ញានិងកិច្ចព្រមព្រៀងបន្ថែម ក្រោមអនុសញ្ញានេះ។